- Tassanavadey Mittasalabaley

R 6 71- 3-54

- Revue amicale des Écoles de Pali -

INDOCHINE … DÉPÔT LÉGAL

Janvier 1954

ឆ្នាំទី ៣

ថ្ងៃទី ១

# ទស្សនាវដ្ដី
# មិត្តសាលាបាលី

លេខ ១

ខែមករា

ផ្សាយចេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

ព.ស. ២៤៩៦ ចេញរាល់ថ្ងៃទី១នៃ

គ.ស. ១៩៥៤ ប្រក្រតិទិនសុរិយគតិ



ទីចាត់ការនៅវត្តលង្កា

សង្កាត់លេខ ៦ ក្រុងភ្នំពេញ

មិត្តដែលបានអានទស្សនាវដ្ដីនេះរាប់ទុកជាបានជួយលើកដំកើង

សាសនា អក្សរសាស្ត្រ និង ព្រះមហាក្សត្រ របស់ខ្លួន

បណ្ណាធិការ ហួត · ទៀម

# មាតិការឿង

យោបល់របស់សម្ដេចសង្ឃរាជ ៣ ព្រះអង្គ

| | | |
|---|---|---|
| បណ្ណាធិការ | | សេចក្ដីពិសេស |
| " | | វិចារណកថា |
| ព្រះឧបាលិវង្ស សុ. ហាយ | ........................ | សីលធម៌ |
| បណ្ណាធិការ | ........................ | អ្នកជាគោលរបស់ជាតិ |
| លោក ក៉យ ប៊ុក | ........................ | អក្សរសាស្ត្រខ្មែរ |
| មហាសមន | ........................ | ពត៌មានគួរធ្វើខ្លះគួរគិតខ្លះ |
| ឃោសនាការ | ........................ | មហាសន្និបាត នៃសមាគមគិលានសង្គ្រោះ |
| បណ្ណាធិការ | ........................ | បកិណ្ណកកថា |
| ព្រះមហា ប៉ាង់-ខាត់ | ........................ | រឿងបញ្ចតន្ត្រៈ |
| បណ្ណាធិការ | ........................ | ប្រវត្តិនៃកន្ទុំក្រពាម្ចាក់ |

---

## តំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ខែ | ១ឆ្នាំ | ១ក្បាល |
| ៤៥៖០០ | ៩០៖០០ | ៤រ.០០ | ៥៥រ.០០ | ១០៥រ.០០ | ១ ០រ.០០ |

អ្នកទទួលចេញជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*

សូមអស់លោក ចាំអាន សាសនាប្រទេសជប៉ុន ទៅស្នងទន្សាយធ្វើដំណើរតាមពាក្យលោក ទឹងវឿង រូបតុក្កតា រចនា ទេពិដាត មៅទស្សនាវដ្ដី លេខ ២ អស់លោកនឹងបានទទួលសេចក្ដីពេញចិត្តជាយច្រើនមិនខាន ។



យោបល់

លេខ ១១

វត្តបទុមវតី ក្រុងភ្នំពេញ

ក្រសួងព្រះសង្ឃនាយក គណៈធម្មយុត្តិ

ថ្ងៃ១ ៗ ៣ ឆ្នាំម្សាញ់ បញ្ចស័ក
១១
ព.ស. ២៤៩៦ គឺថ្ងៃ២៨ ខែកុម្ភៈ ឆ្នាំ ១៩៥៤ ។

សម្ដេចព្រះសុគន្ធាធិបតី សង្ឃនាយក គណៈធម្មយុត្តិ

ចំរើនពរមកលោកបណ្ណាធិការទស្សនាវដ្ដី មិត្រសាលាបាលី

សូមជ្រាប!

រឿងដែលលោកទូលស្នើ សុំយោបល់អាត្មាភាពនោះ បានពិនិត្យសព្វគ្រប់ហើយ យោបល់អាត្មាភាពយល់ឃើញថា: រឿងដែលលោកគិតផ្ដើមធ្វើទស្សនាវដ្ដីនេះឡើងវិញ គឺស្រេចនៅលើគណៈកម្មការគ្រប់រូប យល់ឃើញថា ធ្វើទៅបានសេចក្ដីចំរើន អាត្មាភាពក៏ពុំមានយល់ទាស់ ។



យោបល់

សមាគមមិត្រសាលាបាលី បានចាប់កំណើតឡើងពីក្នុង ព.ស. ២៤៩២ គ.ស. ១៩៤៩ បានជួយឧបត្ថម្ភ ដល់ពួកសិស្សសាលាបាលីជាន់ខ្ពស់ ដែលប្រឡងជាប់បានសញ្ញាបត្រ រាល់ឆ្នាំ តាំងពី គ.ស.១៩៥០រៀងមក ដោយបានធ្វើព្រហ្មទេយ្យ ជាអំណោយ ដែលកាលពីមុនមក សាលាបាលីជាន់ខ្ពស់ពុំធ្លាប់ដែលមាន ទោះបីមានព្រហ្មទេយ្យខ្លះកើតឡើង ដោយសទ្ធារបស់ពុទ្ធបរិស័ទ្យចូលចាប់កុសល ក៏គង់រាប់បាន កើតឡើងដោយការឃោសនារបស់សមាគមមិត្រសាលាបាលីដែរ ។ ម្យ៉ាងទៀតក្រៅពីនោះ ក៏សមាគមនេះបានជួយទំនុកបំរុងតាមគួរដល់ការណ៍ដែរ ។

គួរឲ្យមានសេចក្ដីសង្ឃឹមថា សមាគមមិត្រសាលាបាលីនេះនឹងចេះតែចំរុងចំរើនឥតអាក់ខាននិច្ចនិរន្តរ៍រហូតទៅ ដោយសារការឧបត្ថម្ភរបស់ពុទ្ធបរិស័ទ ក្នុងកម្ពុជរដ្ឋទាំងមូល សូមប្រសិទ្ធិពរ ឲ្យសមាគមមិត្រសាលាបាលីនេះមានបដិវត្តន៍ប្រព្រឹត្តទៅដោយប្រពៃ កុំបីមានការណ៍ចង្អៀតចង្អល់មករាំង ដោយប្រការណាមួយឡើយ !

ថ្ងៃ ២៦ កុម្ភៈ ១៩៥៤

សម្ដេចព្រះមហាសុមេធាធិបតី

(ជ. ណា. ជោតញ្ញាណោ)



យោបល់

ទស្សនាវដ្ដីមិត្តសាលាបាលី ចាត់ទុកជាដំហានទី ១ ដែលធ្វើសាសនចក្រឲ្យមានដំណើរស្រុះស្រួលនឹងអាណាចក្រ បង្កើតវឌ្ឍនភាពដល់ប្រទេស ដែលទើបនឹងទទួលផលឯករាជ្យជាលើកដំបូង ។ អាត្មាភាព មានសេចក្ដីស្ដាយជាអនេកកាលពីឆ្នាំ១៩៥៣ ទស្សនាវដ្ដីនេះបានបាត់បង់ទៅ ដោយអ្នកជួយជាវជួយអានល្មមការប្រព្រឹត្តទៅបានស្រួលនៃទស្សនាវដ្ដីនេះពុំគ្រប់គ្រាន់ៗដល់ឆ្នាំ១៩៥៤នេះ ទស្សនាវដ្ដីមិត្តសាលាបាលី បានចាប់កំណើតជាថ្មីឡើងវិញទៀត អាត្មាមានសេចក្ដីរីករាយណាស់ ចំពោះការចាប់កំណើតជាថ្មីឡើងវិញថា មុខជាមានដំណើរដ៏ប្រពៃទៅតាមកាលៈទេសៈនៃពុទ្ធសាសនា ដែលកំពុងតែមានការនិយមនៃសិរីលោកទាំងឡាយ ។

ទីបំផុតអាត្មាសូមប្រសិទ្ធិពរ ដល់គណៈកម្មការទស្សនាវដ្ដី ដែលមានសទ្ធាចិត្តស្មោះចំពោះព្រះពុទ្ធសាសនាប្រឹងជួយឧបត្ថម្ភ, ដោយការបង្កើតទស្សនាវដ្ដីនេះ ឲ្យមានអាយុជីវិតគង់វង្សលុះទីបំផុត និងឲ្យប្រជាជនទាំងគ្រហស្ថ បព្វជិតនិយមរាប់អានឲ្យបានច្រើនទូទៅក្នុងលោក ព្រោះទស្សនាវដ្ដីនេះពិតជាជួយតម្កើងព្រះពុទ្ធសាសនានិងអក្សរជាតិ ។

ព្រះហស្ថលេខា

សម្ដេចព្រះធម្មលិខិត ឧត្តមប្រឹក្សា (ល្វី-ឯម)

# សេចក្ដីពិសេស

កាលពីឆ្នាំ ១៩៥០ ទស្សនាវដ្ដីមិត្តសាលាបាលីបានចាប់កំណើតឡើងជាលើកដំបូង, ទារកទស្សនាវដ្ដីក្នុងពេលនោះមានកំឡាំងរឹងប៉ឹងជាខ្លាំង ប្រសូត្រភ្លាមអាចស្រែកបញ្ចេញសំឡេងយ៉ាងពីរោះគួរចាប់ចិត្ត, ដល់បរិវៀនវ័យបន្តិចមកសាច់ឈាមកំឡាំងកាយក៏ប្រែជាថមថយបន្តិចម្ដង ៗ ធ្វើឲ្យកុមារដែលទើបតែមានអាយុបានបីឆ្នាំ ត្រូវជម្ងឺរបេងគ្របសង្កត់ជាខ្លាំង បណ្ដាលឲ្យវេជ្ជបណ្ឌិតទាំងឡាយដែលមានថ្វីដៃ ប្រឹងកែកុនរកឱសថវិសេសគ្រប់យ៉ាង មកព្យាបាលពេលនោះ ទោះបីប្រើឱសថវិសេសបែបណាក៏ដោយគង់រក្សាជីវិតទារកទស្សនាវដ្ដីនោះឲ្យគង់ទ្រង់នៅពុំបាន ៗ ក្នុងថ្ងៃទី ៣១ ធ្នូ ឆ្នាំ ១៩៥២, ទារកទស្សនាវដ្ដីមិត្តសាលាបាលីបានបែកឋានទៅកាន់លោកខាងមុខហើយ, ធ្វើឲ្យជនជាទីស្នេហាទាំងឡាយសោកស្ដាយជាអនេក, គ្រូអ្នកព្យាបាលបានបូជាយកធាតុដំកល់ទុកនៅមន្ទីរចាត់ការសមាគម ៗ

ដោយហេតុតែទារកនោះពុំទាន់ដាច់អាល័យក្នុងកិច្ចកសាងជីវភាពរបស់ខ្លួនទើបទារកកំសត់នេះបានចូលមកយកកំណើតសាជាថ្មីឡើងវិញ; ក្នុងថ្ងៃ ១ មករា ឆ្នាំ ១៩៥៤ កំណើតនៃទារកថ្មីនេះបានប្រសូតឡើងហើយ មានរូបរាងនិងពណ៌សម្បុរ ប្លែកជាងមុនបន្តិច តែមានពលភាពដូចជាទន់ខ្សោយជាងមុន, ដោយកើតឡើងភ្លាម មាតានៃកុមារនេះពុំសូវគ្រប់គ្រាន់ទឹកដោះចិញ្ចឹមទារករបស់ខ្លួន ៗ សូមអស់លោកអ្នកអានទាំងឡាយជ្រាបបានថាសម្រែកនៃទារកទស្សនាវដ្ដីកំសត់នេះ មានសំឡេងពុំសូវគាប់ដល់សោតប្រសាទនៃលោកអ្នកប៉ុន្មានទេ ព្រោះគ្នាមានកំណើត ដល់ទៅពីរសាទៅហើយ បើស្រែកយំឡើងពុំជាទីគាប់អធ្យាស្រ័យដល់អស់លោកអ្នកខ្លះក៏សូមមេត្តាកុំប្រកាន់ ៗ ដូចម្ដេចក៏ដោយកុមារទស្សនាវដ្ដីមិត្តសាលាបាលីសូមផ្លាស់សម្រែកខ្លះ នឹងកុំឲ្យពីរោះខ្លាំងពេក លោកអ្នកអានប្រែជាទន់ត្រចៀកដូចពេលមុន ក្នុងសម័យនោះឮថា ធម៌ច្រើនពីរោះខ្លាំង ងុយក៏ខ្លាំងដែរ ហេតុដូច្នេះសូមផ្សំគ្រឿងបន្តិចដើម្បីនឹងផ្លាស់ជីវសថ្មី កែលោកអ្នកអានកុំឲ្យងោកងុយពេក ៗ

ទីបំផុតទារកទស្សនាវដ្ដីសូមផ្ញើសេចក្ដីមេត្រីដ៏ស្មោះចំពោះជីវភាពថ្មីរបស់ខ្លួន សូមឲ្យលោកអ្នករួមជាតិទាំងឡាយជួយគាំទ្រតាមឋានៈជាជនអ្នកស្នេហាចំពោះជាតិ - សាសនា - ព្រះមហាក្សត្រ និងអក្សរសាស្ត្រសម្រាប់ជាតិរបស់ខ្លួន ដោយការជួយអាន ជួយលើកដំកើង ៗ

# ព្រះពុទ្ធសាសនានៅអាស៊ីទ្វីប

លទ្ធិពុទ្ធសាសនានៅទ្វីបអាស៊ីយើងនេះ ចែកជាពីរយ៉ាង គឺ ហីនយាន ១ មហាយាន ១ ។ លទ្ធិទាំងពីរនេះមានកាន់ស្មើរតែគ្រប់ប្រទេសនៅអាស៊ីទ្វីប តែលទ្ធិហីនយានមានភាគច្រើនជាង ។ លទ្ធិទាំងពីរនេះ ទោះបីអ្នកកាន់មានការប្រតិបត្តិខុសគ្នាខ្លះក្តី គឺនៅជាកាន់តាមគោលនៃព្រះពុទ្ធសាសនាដែរ ។ ហេតុនេះហើយបានជា - ពុទ្ធសាសនិកជនទាំងឡាយទាំងខាងហីនយាន ទាំងខាងមហាយានប្រឹងបងបាច់គ្នា ក្នុងដំណើរការចម្រើននៃព្រះពុទ្ធសាសនា ។ សព្វថ្ងៃនេះ ខាងហីនយានក៏មិនមានអស្មិមានះប្រកាន់ថាខ្លួនជាអ្នកត្រាន់បើជាងមហាយាន, ខាងមហាយានក៏មិនប្រឆាំងនឹងខាងហីនយានដែរ មានតែឈមមុខរកគ្នា ដើម្បីរកចំណងភាតរភាព ខាងព្រះពុទ្ធសាសនាឲ្យជាប់ជិតស្និទ្ធលើសដើម; ដូចគេបានបង្កើតសមាគមព្រះពុទ្ធសាសនាមួយឡើងឲ្យជារបស់កណ្តាល មានទីសំណាក់ការបណ្តោះអាសន្ននៅលង្កាទ្វីប ហៅថា „ពុទ្ធិកសមាគមពិភពលោក” សមាគមនេះ បានធ្វើធំមហាសន្និបាតព្រះពុទ្ធសាសនា លើកទី១នៅលង្កាទ្វីប ក្នុង ព.ស. ២៤៩៣ គ.ស ១៩៥០ ពុទ្ធសាសនិកជនទាំងបព្វជិត ទាំងគ្រហស្ថអំពីនានាប្រទេសបាននៅរួបរួមប្រជុំដោយរីករាយ; អ្នកផងចាំបានថា ប្រទេសខ្មែរយើងសម្តេចព្រះមហាសុមេធាធិបតី ជួនណាត សង្ឃនាយកគណៈមហានិកាយ បាននិមន្តជាប្រធានគណៈប្រតិភូប្រទេសខ្មែរទៅប្រជុំពិភាក្សាផងជាមួយនឹងគណៈប្រតិភូប្រទេសឯទៀត ២៨ ប្រទេស; មហាសន្និបាតលើកទី២នៅប្រទេសជប៉ុន ក្នុង ព.ស. ២៤៩៦ គ.ស. ១៩៥៣, នៅមហាសន្និបាតនុ៎ះ ក៏មានអ្នកពុទ្ធសាសនាទាំងបព្វជិតទាំងគ្រហស្ថជាច្រើនប្រទេស បានទៅប្រជុំពិភាក្សាគ្នាដោយមេត្រីភាព; គេចាំបានថាប្រទេសខ្មែរយើងព្រះតេជព្រះគុណព្រះគោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ បាននិមន្តជាប្រតិភូខ្មែរ ទៅប្រាស្រ័យទាក់ទងគ្នានឹងប្រតិភូនានាប្រទេស យ៉ាងរាក់ទាក់ជាទីបំផុតវិស័យដូចបងប្អូនដែលប្រសូតចេញចាកឧទរមាតាតែមួយ ។ មហាសន្និបាតលើកទី ១នឹងលើកទី២ នេះស ឲ្យឃើញថាក្នុងសម័យនេះ ពួកអ្នកពុទ្ធសាសនាកំពុងតែមានសាមគ្គីចងជាប់គ្នាយ៉ាងខ្លាំង ដែលគួរចាត់ទុកជាចំហានដំបូងនៃសន្តិភាពពិភពលោក បើប្រសិន

ជាអាចចាត់ការទៅបានដោយស្រួលតាមគោល-បំណងនោះពិតមែន ។ នៅព.ស. ២៤៩៦ គ.ស. ១៩៥៤ ទើបមានធ្វើមហាសន្និបាតព្រះពុទ្ធសាសនានៅប្រទេសភូមាទៀត ជាលើកទី ៣ មានទាំងប្រហែលគ្នា ប៉ុន្តែលើកនេះមានការសង្គាយនាព្រះត្រៃបិដកផង ដែលប្រទេសនេះបានចម្លងយកបែបព្រះត្រៃបិដកបាលីប្រែពីប្រទេសខ្មែរយើងទៅជាគំរូ ។ មហា-សន្និបាតលើកទី ៣ តាមដែលគេគ្រោងទុកថា នឹងធ្វើដល់ ២ ឆ្នាំ ទើបបានសម្រេច ។

គង់ពេលដែលអ្នកពុទ្ធសាសនា កំពុងតែនាំគ្នាពង្រីកលទ្ធិពុទ្ធសាសនាដូចពណ៌នាមកនេះដើម្បីញ៉ាំងសន្តិភាពឲ្យកើតមានដល់សាកលលោក, ស្រាប់តែមានប្រទេសពុទ្ធសាសនាខ្លះនៅទ្វីបអាស៊ី ត្រូវសង្គ្រាមលទ្ធិដែលចំនាស់នឹងព្រះពុទ្ធសាសនា កំពុងគម្រាមសព្វថ្ងៃ តើដឹងជាប្រទេសនោះដោះខ្លួនរួចឬទេ ? ពេលដែលអ្នកពុទ្ធសាសនានៅប្រទេសណា កំពុងមានទុក្ខវេទនាដោយសង្គ្រាមលទ្ធិគេបសង្កត់ យើងជាពុទ្ធសាសនិកនៅកម្ពុជរដ្ឋ ក៏សូមចូលកាន់ទុក្ខសញ្ញាជាមួយនឹងអ្នកពុទ្ធសាសនានៅប្រទេសនោះផង ទាំងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងសាកលលោកសូមឲ្យជួយប្រទេសពុទ្ធសាសនាទាំងនោះ ព្រមទាំងប្រទេសកម្ពុ-ជាយើងឲ្យមានជ័យជំនះ នឹងបានសន្តិសុខក្សេមក្សាន្តដោយស្រួល ដើម្បីត្រួតដៃគ្នាពង្រីកភាតរភាពរវាងអ្នកពុទ្ធសាសនា ឲ្យចម្រើនជាកិយ្យាភាពតទៅ ។

ជយោព្រះពុទ្ធសាសនា

ពុទ្ធបុត្ត

## សីលធម៌របស់មនុស្ស

ទសធម្មសូត្រត្រង់អង្គបទ ទី ៤ ថា " បព្វជិតគប្បីពិចារណារឿយ ៗ ថា ខ្លួនអាត្មាអញតិះដៀលខ្លួនឯងដោយសីលធម៌បានឬទេ?" សីលធម៌ក្នុងសូត្រនេះមិនមែនចំពោះតែបព្វជិតទេ គឺជាសាធារណៈដល់បព្វជិតផងគ្រហស្ថផង ។

ពាក្យថា "សីលធម៌" នេះ បារាំង ហៅថា moralité បានដល់ចុកមារយាទល្អ, កិរិយាប្រព្រឹត្តត្រឹមត្រូវ, ការដំកល់ខ្លួនឲ្យមានសណ្តាប់ធ្នាប់, ការប្រព្រឹត្តវៀរយប្រាសចាកទោស, ការចេះទុកដាក់ខ្លួនដោយការរក្សាកាយវាចាឲ្យផុតអំពីទោសពៃរ៍ដែលអ្នកផងគួរតិះដៀល, ការចេះធ្វើបដិសណ្ឋារៈតាមសមគួរដល់ឋានៈនៃបុគ្គលគ្រប់ថ្នាក់, ការចេះធ្វើខ្លួនឲ្យមានបរិយាល្អឲ្យសមស័ក្តិ ជាឥត្ថីភាពបុរសភាព ដែលមានត្រកូលដ៏ល្អទាំងនេះ ហៅថា "សីលធម៌" ។

សីលធម៌នេះ រាប់ថាជាសម្បត្តិល្អរបស់មនុស្ស ឬថា សីលនេះទុកដូចជាសញ្ញាប័ត្រជាគ្រឿងសំគាល់

របស់មនុស្សល្អ ៗ មួយទៀតសីលធម៌នេះ ទុកជាច្បាប់ពិសេសមួយសម្រាប់ពត់និស្ស័យរបស់មនុស្សដែលធ្លាប់មានចុកមារយាទគ្រោតគ្រាត អាក្រក់ឲ្យទៅជាមនុស្សមានកិរិយាប្រព្រឹត្តិរៀបរយល្អ ៗ

ការប្រព្រឹត្តិត្រឹមត្រូវតាមបញ្ញត្តិ, ក្រឹត្យ, ក្រមដែលចេញជាផ្លូវការក្តី, តាមប្រពៃណីធម៌ដ៏ល្អដែលគួរប្រព្រឹត្តគួរជឿកាន់យកក្តីហៅថា "សីលធម៌ទាំងអស់" ៗ បុរសស្ត្រីដែល ហៅថា អ្នកមានសីលធម៌នោះ មិនសំដៅយកតែមនុស្សអ្នកមានវោហារចេះពាក្យពេចន៍ ឬមានរូបឆោមលោមពណ៌ល្អ ចេះស្លៀកពាក់មានរបៀបនោះទេ ៗ បុរសស្ត្រីសូម្បីចេះនិយាយពីរោះពិសា មានរូបសម្បត្តិល្អ មានសំលៀកបំពាក់ត្រឹមត្រូវពិតមែន តែបើមានកិរិយាប្រព្រឹត្តិអាក្រក់ដោយកាយវាចា បៀតបៀនអ្នកដទៃ ធ្វើអ្នកដទៃឲ្យខូចសេចក្តីសុខចំរើន គឺធ្វើឲ្យគេមានទុក្ខព្រួយឲ្យវិនាសទ្រព្យវិនាសជីវិត ឬឲ្យខូចផលប្រយោជន៍, បុរសស្ត្រីនោះនឹងហៅថា អ្នកមានសីលធម៌ពុំបានទេ ប្រៀបដូចជាផ្កាឈើខ្លះដែលមានពណ៌ល្អ វិសេសពិតមែន តែគ្មានក្លិនក្រអូប ឬត្រឡប់ទៅជាមានក្លិនស្អុយវិញ, ផ្កាឈើខ្លះមិនមានពណ៌ល្អទេ តែមានក្លិនក្រអូប, ផ្កានេះរមែងជាទីត្រូវការរាប់អានរបស់សាធារណជនទៅវិញបាន ៗ

សីលធម៌នេះ បើសំដែងដោយបរិយាយមានច្រើនយ៉ាង តែក្នុងទីនេះ នឹងសូមចែកសីលធម៌ដោយរួបរួមមានសាខា ៦ យ៉ាង:

១- សីលធម៌សម្រាប់សង្គម,

២- សីលធម៌សម្រាប់ជាតិជាមួយគ្នា,

៣- សីលធម៌សម្រាប់គ្រូនឹងសិស្ស,

៤- សីលធម៌សម្រាប់មាតាបិតាស្វាមី-ភរិយានឹងបុត្តធីតា,

៥- សីលធម៌សម្រាប់ម្ចាស់ផ្ទះនឹងភ្ញៀវ,

៦- សីលធម៌សម្រាប់ទីប្រជុំ ៗ

សូមអធិប្បាយអំពីសីលធម៌ទាំងនេះតាមលំដាប់មួយម្តង ៗ ដូចសេចក្តីតទៅ ៖

## ១- សីលធម៌សម្រាប់សង្គម

លំនៅរបស់ប្រជាជនដែលនៅរួបរួមក្នុងផ្ទះជាមួយគ្នាក្តី, ផ្ទះដោយខ្លួនពីគ្នាតែនៅភូមិជាមួយគ្នាក្តី, ក្នុងឃុំក្នុងសង្កាត់ជាមួយគ្នាក្តី, ក្នុងស្រុក-ខេត្តជាមួយគ្នាក្តី, រហូតដល់ប្រទេសទាំងមូលក្តី; នេះហៅថា "សង្គម" ព្រោះជាជាករណីយកិច្ចរបស់ប្រជាជនទាំងអស់ សុទ្ធតែជាប់ទាក់ទងនឹងគ្នាត្រូវពឹងពាក់អាស្រ័យគ្នាទៅវិញទៅមកជាដរាប ទើបប្រព្រឹត្តទៅដើម្បីសេចក្តីសុខ-ចំរើនដោយស្រួលបាន ៗ ការពឹងប្រាស្រ័យគ្នានេះតែងមានជាទំនៀម បើមិនច្រើនក៏តិច, កាលៈបើជនរួមសង្គមបានជួបគ្នាម្តងៗ ឬជួបគ្នាដោយញឹកញាប់ក៏ត្រូវតែរាប់អានគ្នា, ត្រូវទទួលស្គាល់គ្នាដោយស្មោះត្រង់, ត្រូវចំណាំមុខគ្នា ត្រូវចំណាំគោត្តនាមបកតិនាមគ្នាទៅវិញទៅមកដើម្បី

សាងដែនមិត្តភាពចងស្ពានមេត្រីរកគ្នាពីម្នាក់ទៅម្នាក់, ពីផ្ទះមួយទៅផ្ទះមួយ, ពីភូមិ ១ ទៅភូមិ ១, ពីឃុំមួយទៅឃុំមួយ; ពីស្រុកមួយទៅស្រុកមួយ, ពីខេត្តមួយទៅខេត្តមួយ ឲ្យជាប់ជាមិត្តភ័ក្ដិរួមសាមគ្គីរីកធំទូលាយ ទូទៅពេញទាំងប្រទេស ទុកដូចជាបានធ្វើសន្និសញ្ញារវាងប្រជាជនក្នុងសង្គមទាំងអស់ ៗ ពលរដ្ឋក្នុងប្រទេសនីមួយ ៗ, កាលបើមានសីលធម៌ គឺមានសេចក្ដីស្និទ្ធស្នាល ស្នេហាស្មោះត្រង់ចំពោះគ្នានឹងគ្នាទាំងអស់ដោយមេត្តាករុណា ឥតមានសល់អ្នកណាម្នាក់ដែលមិនមានស្រឡាញ់គ្នាយ៉ាងនេះ តើប្រជាជនក្នុងសង្គមនោះ១ អាចនឹងបៀតបៀនគ្នា, មានចិត្តវៀចក្បត់នឹងគ្នាដូចម្ដេចកើត?

សីលធម៌នេះជាគោលច្បាប់មួយ ដ៏ប្រសើរបំផុតដែលអាចឲ្យផលជាសុខសន្តិភាពក្នុងរវាងប្រជាជនក្នុងសង្គមដោយជាក់ច្បាស់ក្នុងបច្ចុប្បន្ននេះ ។

## ២_ សីលធម៌សម្រាប់ជាតិ

ពាក្យថា "ជាតិ" នេះជាភាសាបាលី ប៉ុន្តែខ្មែរយើងយកមកប្រើនិយាយជាញឹកញយរហូតទាល់តែស្ដាប់បានចូលចិត្តដោយច្បាស់លាស់, សូម្បីអ្នកមិនចេះបាលីក៏ស្ដាប់យកសេចក្ដីបានឥតសង្ស័យ ។ ប្រជាជនរបស់ប្រទេសយើងមានចំនួនតិច, មានពាក្យសម្រាប់ប្រើក៏តិច បើត្រូវការនិយាយ ឬសរសេរក្រៅផ្លូវការក្ដី, ក្នុងផ្លូវការក្ដី ក៏រមែងលំបាកដោយហេតុតែខ្វះខាតពាក្យពេចន៍មិនគ្រប់គ្រាន់ក្នុងការប្រើ ព្រោះហេតុនោះបានជារដ្ឋាភិបាលបានបង្កើតគណៈកម្មការវប្បធម៌ឡើងដើម្បីបណ្ដុះបណ្ដាលបង្កើតពាក្យបន្ថែមទៀតឲ្យមានសម្បូណ៌ឡើង ; ខ្មែរយើងធ្លាប់ជាប់ទាក់ទងដោយភាសាបាលីនិងសំស្ក្រឹតជាយូរលង់ណាស់ អស់រវាង ២០ សតវត្សរ៍មកហើយ, ក្នុងពេលប្រជុំសមាជិកនៃគណៈកម្មការវប្បធម៌ រកពាក្យពេចន៍ជ្រើសរើសនោះ មានការត្រិះរិះស្វែងរកដោយពេញសមត្ថភាពតែរៀង ១ ខ្លួនដើម្បីយកពាក្យនោះ ៗ មកប្រើឲ្យខ្វីហើយឲ្យស្រណុកថា, ឲ្យងាយហៅ, ហើយឲ្យស្រួលស្ដាប់ផង ។ ពាក្យវប្បធម៌នេះ អ្នកដែលមានអស្មិមានះ ឬដែលជាមនុស្សពាលក្នុងផ្លូវអក្សរសាស្ត្រខ្មែរតែងរិះគន់ពេបជ្រាយថាឲ្យដូចេះដូចោះ តាមវោហាររបស់គេមិនខាន ។ ពាក្យរិះគន់នេះតែងមានជាធម្មតា បាលីក្នុងផ្នែកលោកធម៌ ហៅថានិន្ទា ប្រែថារិះគន់ឬតិះដៀល ។

ទោះបីពាក្យបាលី ឬសំស្ក្រឹតពិតមែន តែបើយើងយកមកប្រើប្រាស់និយាយជាញឹកញយយូរ ៗ ទៅ ក៏អាចស្ដាប់បានសន្និដ្ឋានកើតពុំលែង ដូចពាក្យថា សន្និសីទ, នគរ, រដ្ឋ, ប្រទេស, ថវិកា, ធម្មការ, តុលាការ, ប្រៃសនីយ៍, រដ្ឋាភិបាល, រដ្ឋករប៉ុណ្ណោះជាដើម សុទ្ធតែពាក្យបាលីសំស្ក្រឹតទាំងអស់ ។ យើងបានយកពាក្យនេះមកប្រើជាផ្លូវការ ឬប្រើនិយាយធម្មតាយូរៗទៅគេក៏ស្ដាប់បានស៊ើរតែគ្រប់គ្នាអស់ទៅហើយ ។ ពាក្យរិះគន់នោះមុខជានឹងសាបសូន្យអសារបង់ទៅមិន

ខាន ៗ បើប្រសិនជាពាក្យរិះគន់នោះវង្វេងវង្វាំងរស់នៅដោយស្ងិតស្ងាញបានយូរតទៅ ប្រហែលជានឹងហាមាត់និយាយ ឬសរសេរសៀវភៅក្ដី, កាសែតក្ដី, បានដោយលំបាកដែរមើលទៅ !

ពាក្យថា "ជាតិ" នេះប្រែថា "កំណើត", ថា "ការកើតប្រាកដឡើងនៃខន្ធ" ។ ជាតិនេះបានដល់កំណើតរបស់មនុស្សសត្វក្នុងសាកលលោក ។ បាលីហៅថា ជាតិដូច្នេះក៏មាន ហៅថា វណ្ណៈ ក៏មានៗ ក្នុងសម័យពុទ្ធកាល ប្រទេសឥណ្ឌាចាត់ វណ្ណៈនេះចេញជា ៤ ពួក គឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សូទ្រៈ ១ ។ វណ្ណៈ ទាំង ៤ នេះ មានសេចក្ដី ប្រកាន់យកសីលធម៌ផ្សេង ៗ គ្នាដោយពួក ៗ ឥតមានសីលធម៌រលាយចូលគ្នាសោះ ។ ព្រះសម្មាសម្ពុទ្ធបានត្រាស់ដឹងឡើងទ្រង់សំដែងធម៌ បញ្ញត្តិវិន័យរំលាយសីលធម៌របស់វណ្ណៈទាំង ៤ នោះ ឲ្យរលាយចូលគ្នាបានរហូតដល់មកសព្វថ្ងៃនេះ ។ ព្រះសម្មាសម្ពុទ្ធឈ្មោះថាព្រះអង្គបានរំលាយ វណ្ណៈ ៤ ពួកនោះឲ្យរួមមកនៅតែវណ្ណៈមួយប៉ុណ្ណោះ ព្រោះថាព្រះអង្គបានធ្វើការបរិវត្តន៍ឲ្យវណ្ណៈទាំងនោះ មានសីលធម៌ប្រសើរកើតចំលាយឡើងដើម្បីឲ្យមូលសាមគ្គី ឲ្យមានឥទ្ធិពលក្នុងវង់ជាតិតទៅ ដើម្បីជាតម្រាប់ដល់យើងដែលត្រូវការដោយធម៌សាមគ្គី ។

យើងជាប្រជាជនជាតិខ្មែរ មិនសូវមានសេចក្ដីប្រកាន់កំណត់វណ្ណៈជាក់លាក់ដូច្នោះទេ តែគង់មានខ្លះដោយជាប់អនុស័យធម៌ក្នុងសន្ដាន ដូចប្រកាន់ថា "អញជាជាតិអ្នកមានទ្រព្យ, មានយសស័ក្ដិអំណាច, មានត្រកូលខ្ពស់, មានឋានៈជាធំដូច្នេះជាដើម ។

ការប្រកាន់ជាតិនេះទុកជាទោសមួយយ៉ាងធំបំផុតដែលនាំឲ្យធ្លាយខូចសីលធម៌ក្នុងវង់ជាតិរបស់ខ្លួន កាលបើខូចខាតសីលធម៌ហើយ តើសាមគ្គីធម៌នឹងឋិតនៅដូចម្ដេចកើត ? អត្ថបទនេះគួរយើងពិចារណានឹករលឹកឲ្យចាំជាប់កុំឲ្យភ្លេចថា "អាត្មាអញនេះនឹងអ្នកនោះមានជាតិត្រូវគ្នា, កាន់សាសនាត្រូវគ្នា, រួមនៅក្នុងអំណាចរដ្ឋាភិបាលជាមួយគ្នាប៉ុណ្ណោះជាដើម" ; មួយទៀត, សីលធម៌សម្រាប់ជាតិនេះទុកជាបញ្ហាមួយដែលយើងកល់គ្នាច្រើនតែដឹងច្បាស់ស្មើគ្រប់ ៗ គ្នា តែមិនងាយនឹងដោះស្រាយឲ្យរួចស្រឡះសោះ ។ ដូចពាក្យថា "ស្នេហាជាតិ" ឬថា "អ្នកស្រឡាញ់ជាតិ" តែងចេះថា, ចេះនិយាយតែគ្រប់ៗរូបប៉ុន្តែត្រង់ការគោរពដល់ជាតិ, ធ្វើការសុចរិតដើម្បីជាតិ, បំរើជាតិដោយយុត្តិធម៌ពិតៗ នោះ មិនមែនជាការងាយឡើយ ។ ពាក្យថា "ស្នេហាជាតិ" នោះមិនមែនគ្រាន់តែជាទ្រឹស្ដីប៉ុណ្ណោះទេ គឺជាពាក្យនាំឲ្យយើងបំពេញកិច្ចប្រតិបត្តិផ្ទាល់ខ្លួនចំពោះជាតិយើងជាមុនជាដំបូង ទើបសម្រេចប្រយោជន៍ក្នុងពាក្យថាស្នេហាជាតិទៅបាន ។

ការចេះគោរពកោតក្រែងចំពោះជាតិរបស់ខ្លួនដោយសុទ្ធចិត្ត ដោយមេត្តាស្មោះត្រង់មិនគម្រាម រឺបជាន់ឬប្រមាថដល់ជាតិនេះជាគុណធម៌ដ៏ប្រសើរដែល

នាំឲ្យពួកជនជាតិតែមួយ មូលត្រកួលរកគ្នាត្រជាក់នឹងគ្នាក្នុងរវាងអ្នកធំនិងអ្នកតូច រលាយចូលគ្នាដូចជាទឹកនឹងទឹក ។ ការសំដែងមិត្តភាពគោរពតាមឋានៈ ចំពោះជាតិរបស់ខ្លួនដោយហេតុមានការមិនបៀតបៀន, មិនធ្វើនៃផ្លូវបេះជាដើមដូចបរិយាយមកនេះ ឈ្មោះថាសីលធម៌សម្រាប់ជាតិ ។

## ៣_ សីលធម៌សម្រាប់គ្រូនិងសិស្ស

គ្រូនិងសិស្សតែងមានកិច្ចប្រាស្រ័យនឹងគ្នា រកគ្នាតាមកាលវេលាដែលត្រូវការ ។ ការប្រាស្រ័យគ្នានេះបើតាមស្ថានភាពរបស់មនុស្សមានថ្នាក់ផ្សេងៗគ្នា ដូចអ្នកខ្លះជាមិត្តភក្តិនឹងគ្នាស្និទ្ធហួសពេក, កាលបើជួបគ្នាម្តងៗ ជួនកាលជេរគ្នាលេង, ជួនកាលលូកដៃទៅត្បូកក្បាលគ្នាលេង ។ គួមិត្តភក្តិដែលស្និទ្ធស្នាលនឹងគ្នាហួសពេករហូតទាល់តែគោរពគ្នាដោយការជេរគ្នា ត្បូកក្បាលគ្នាដូច្នេះ មិនរាប់ថាជាអ្នកមានសីលធម៌ល្អដល់គ្នានឹងគ្នាឡើយ ។ គួមិត្តបែបនេះ សូម្បីនិយាយការណាមួយមែនទែនក៏លែងជឿចិត្តគ្នា យកការមែនទែនទៅជាការលេងធម្មតាទៅវិញ ។

គ្រូអាចារ្យមានឋានៈ ជាបុគ្គលខ្ពង់ខ្ពស់ ដែលសិស្សានុសិស្សត្រូវគោរពបូជា ។ គ្រូអាចារ្យត្រូវប្រកបដោយគុណសម្បត្តិ ៧ ប្រការ ដើម្បីឲ្យសមគួរដល់កិត្តិយសនៃខ្លួនដែលមានឋានៈជាគ្រូអាចារ្យ ។

គុណសម្បត្តិ ៧ ប្រការនោះ គឺៈ

១_ ប្រុងទុកដាក់ខ្លួនឲ្យជាទីស្រឡាញ់របស់សិស្ស,

២_ ធ្វើខ្លួនឲ្យសមគួរល្មមជាទីគោរពរបស់សិស្ស,

៣_ អប់រំនិស្ស័យឲ្យបានល្អគួរឲ្យសិស្សសរសើរ,

៤_ ឧស្សាហ៍ទូន្មានសិស្សដោយផ្សំវិធីត្រូវ,

៥_ អត់ធ្មត់ចំពោះពាក្យពោលរបស់សិស្ស,

៦_ ឧស្សាហ៍និយាយពន្យល់ពាក្យជ្រាលជ្រៅឲ្យសិស្សស្តាប់,

៧_ ដឹកនាំសិស្សឲ្យមានសេចក្តីចំរើនក្នុងការសិក្សា ។

ព្រះទេពបាលិវង្ស សួរ-ហាយ (មានត)

---

## អ្វីជាគោលសំខាន់របស់ជាតិ

មនុស្សជាតិក្នុងលោកនេះ តែងមានសាសនាប្រចាំជាតិ ប្រចាំប្រទេស; ប្រជាជនដែលនៅក្នុងប្រទេសមួយៗ មានសេរីភាពក្នុងការជ្រើសរើស ជឿកាន់សាសនាបានតាមចិត្តស្ម័គ្រ ។ គោលធម៌ក្នុងសាសនាប្រដៅឲ្យមនុស្សប្រព្រឹត្តប្រពៃ; សាសនាមានធម៌វិន័យជាគ្រឿងអប់រំចិត្ត ឲ្យមនុស្សឋិតនៅក្នុងសេចក្តីល្អមានសីលធម៌ខ្ពង់ខ្ពស់; បុគ្គលណាប្រព្រឹត្តសាសនា បុគ្គលនោះ អាចនឹងជួយឲ្យមានសេចក្តីសុខសប់-

រៀបរយកើតឡើង ក្នុងប្រទេសរបស់ខ្លួន ។

គ្រប់តែសាសនា សុទ្ធតែមានពាក្យប្រៀនប្រដៅ ឲ្យមនុស្សប្រកបកម្មសុចរិត ខុសគ្នាបន្តិចបន្តួចតែវិធីប្រតិបត្តិប៉ុណ្ណោះ ។ ប្រទេសខ្មែរយើង តាំងពីបុរាណកាលមក មិនដែលមានច្បាប់ ឬព្រះរាជបញ្ញត្តិត្រង់ចំណុចណាមួយ តម្រូវឲ្យប្រជាជនជឿកាន់សាសនាណាមួយ ដោយបំពានឡើយ ។ ក្នុងបច្ចុប្បន្ននេះ, រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រខ្មែរ ក៏មានបទអនុញ្ញាតឲ្យប្រជាជន មានសេរីភាពបរិបូណ៌ក្នុងការជ្រើសរើសយកសាសនាណាមួយ មកកាន់កាប់តាមចិត្តស្ម័គ្រ, មានសេរីភាពក្នុងការធ្វើពិធីកម្មតាមជំនឿរបស់ខ្លួន បើមិនជាទំនាស់ចំពោះនាទីពលរដ្ឋនិងមិនជាទំនាស់ដល់សេចក្ដីសុខរៀបរយ ឬសីលធម៌របស់ប្រជាជនក្នុងប្រទេសខ្មែរ ព្រះមហាក្សត្រទ្រង់ជាពុទ្ធមាមកៈ ទ្រង់ជាអគ្គសាសនូបត្ថម្ភកៈ ព្រោះហេតុថាក្នុងប្រវត្តិការណ៍ រាប់តាំងតែពីប្រទេសបានរួបរួមជាអាណាចក្រតែមួយ មានឈ្មោះថា "កម្ពុជា" មានព្រះមហាក្សត្រជាប្រមុខស្រេចបាច់ហើយ ព្រះអង្គក៏ទ្រង់ទំនុកបំរុងព្រះពុទ្ធសាសនា ប្រជាជនក្នុងព្រះរាជាណាចក្រក៏និយមរាប់អានជឿកាន់ព្រះពុទ្ធសាសនា តាមប្រមុខរបស់ប្រទេស តាំងពីកាលនោះមក ។

ក្នុងបច្ចុប្បន្ននេះ, រដ្ឋធម្មនុញ្ញ មានបទបញ្ញត្តិ លើកព្រះមហាក្សត្រឲ្យជាប្រមុខរបស់ជាតិ និងទ្រង់ជាពុទ្ធមាមកៈនៃព្រះពុទ្ធសាសនា; ដូច្នេះឃើញថា ប្រវត្តិសាស្ត្រប្រទេសកម្ពុជា មានដើមនិងចុងជាប់ជួនពាក់ទងនឹងគ្នាល្អណាស់ចំពោះការគ្រប់គ្រងរដ្ឋនឹងការជឿកាន់ព្រះពុទ្ធសាសនា; ដោយរដ្ឋនិងសាសនាមានការប្រាស្រ័យគ្នាទៅវិញទៅមក ជាប់មិនដាច់យ៉ាងនេះទើបមានបញ្ជាក់សេចក្ដីទុកមកក្នុងប្រវត្តិសាស្ត្រថា "ព្រះពុទ្ធសាសនាជាសាសនារបស់ប្រជាជាតិខ្មែរ" ។

ព្រះពុទ្ធសាសនាឲ្យប្រយោជន៍អ្វីខ្លះដល់ជនអ្នកកាន់ ? ឲ្យវប្បធម៌ សីលធម៌ និងអារ្យធម៌ !

មនុស្សលោកក្នុងសម័យមុនសាសនានោះ ត្រូវប្រាស្រ័យសុខទុក្ខ ជាមួយនឹងធម្មជាតិ វេលាមានភ័យកើតឡើង ក៏នាំគ្នាបន់ស្រន់បួងសួងសូមឲ្យធម្មជាតិ ដូចជាព្រះអាទិត្យ,ព្រះចន្ទ្រ, ទឹក,ដី, ភ្លើង,ខ្យល់ ។ល។ ជួយស្រោចស្រង់ ។ ដោយមនុស្សប្រាស្រ័យ នឹងធម្មជាតិយ៉ាងនេះ ទើបមានពាក្យពោលបញ្ជាក់ក្នុងប្រវត្តិសាស្ត្រថា: មនុស្សក្នុងសម័យបុរាណ មានធម្មជាតិជាសរណៈ; ខាងក្រោយមក ធម្មជាតិទាំងនោះ ក៏បានឡើងឋានៈទៅជាព្រះ គួយ៉ាងព្រះអាទិត្យ, ព្រះចន្ទ្រ, ព្រះធរណី, ព្រះពាយ, ព្រះអគ្គិ ។ល។

តាមធម្មតាមនុស្សលោក ក្នុងសាសនា,កាលបើបានសុខហើយ មុខជាបានទុក្ខជាគូសត្រូវដល់គ្នានឹងគ្នា ដូច្នេះទើបមានមនុស្សពួកមួយ ប្រឹងស្វែងរកឧបាយ ដើម្បីរំលាយបន្ធូរសេចក្ដីទុក្ខរបស់មនុស្ស និងរកផ្លូវមួយបង្ហាញឲ្យមនុស្សដើរតាម; មនុស្សថ្នាក់នេះហើយ ដែលខាងក្រោយមក បានឡើងឋានៈទៅជា

ព្រះឬសាស្តាចារ្យ" ; ពាក្យប្រដៅរបស់សាស្តា ឬព្រះជាម្ចាស់អង្គនោះហៅថា "សាសនា" ។ មនុស្សធម៌ក្តី, សីលធម៌ក្តី អារ្យធម៌ក្តី របស់ប្រជាជនក្នុងលោកនេះ សុទ្ធតែបានមកដោយការសិក្សាសាសនា អប់រំតាមគោលសាសនា ។

នៅក្នុងទ្វីបអឺរ៉ុប, កាលសម័យដើម សាសនចក្រមានអំណាចត្រួតត្រាលើរដ្ឋច្រើនជាងអាណាចក្រ; ការបំពាក់មកុដក្សត្រ្តី ការជំរះវិវាទាធិករណ៍ផ្សេងៗរវាងរដ្ឋក្តី គណៈសង្ឃក្នុងសាសនាជាអ្នកធ្វើ ។ តមកខាងក្រោយ ការសិក្សាខាងផ្លូវលោកនេះ តែងចំរើនឡើងតាមលំដាប់ អាណាចក្រក៏ដណ្តើមយកអំណាច អំពីសាសនចក្រទៅវិញ; តែបើទុកជាដូច្នោះក៏ដោយ, គោលការគ្រប់គ្រងរដ្ឋសព្វថ្ងៃនេះក៏គង់នៅមានមាត្រាច្បាប់ សម្រាប់គ្រប់គ្រងផែនដីជាច្រើន ដែលបានដកស្រង់មកអំពីគោលធម៌ក្នុងសាសនា ។ អ្នកសាសនា បានពិនិត្យដោយម៉ត់ចត់ ហើយបានបញ្ចេញទស្សនៈទុកមកថា: មិនឃើញមានច្បាប់ត្រង់ណា ដែលលោកសាងថ្មីក្រៅអំពីដកស្រង់មកពាក្យសាសនា ចំពោះច្បាប់ដែលធ្វើឲ្យប្រទេសតាំងនៅក្នុងសេចក្តីសុខស្ងប់ ។

នៅក្នុងលោកនេះ បើមិនមានសាសនាជួយបណ្តុះបណ្តាលសីលធម៌ដល់ប្រជាជន លោកក៏មិនមានរបៀបរៀបរយ ខាងផ្លូវចរិយាមារយាទដល់ប៉ុណ្ណោះឡើយ ។

ប្រទេសខ្មែរយើង មានព្រះពុទ្ធសាសនាជាឃ្លាំងមួយសម្រាប់បញ្ចេញសីលធម៌និងសន្តិធម៌ យ៉ាងខ្ពស់បំផុត ប្រសិនបើប្រជាជន យកចិត្តទុកដាក់ ប្រឹងប្រែងខាងពង្រីកសីលធម៌របស់ជាតិ ឲ្យចំរើនឡើងនោះ សាសនានេះនឹងមិនខ្វះគោលធម៌របស់ជាតិបញ្ចេញឲ្យឃើញសោះឡើយ; តែប្រជាជនជាតិយើងមិនសូវស្គាល់ខាងសីលធម៌ប្រចាំជាតិ ប្រចាំខ្លួនទេ ទើបត្រូវបានទទួលផលផ្ទុយទៅវិញ ។ ដើម្បីនឹងកែកំហុសរបស់ជាតិក្នុងរឿងនេះ រដ្ឋាភិបាល និងពុទ្ធមាមកៈ ក្នុងប្រទេសយើង គួរតែរួមដៃគ្នា សាងអគ្គការមួយឡើង ឲ្យឈ្មោះថា "អគ្គការអប់រំសីលធម៌ ឬចរិយាសិក្សា" ។ អគ្គការនេះ វេលាបានសាងឡើងត្រូវបញ្ជូលទៅក្នុងសាលារៀនគ្រប់ថ្នាក់ដោយជ្រៀតយកពេលអំពីអ្នករៀន តាមកម្មវិធីធម្មតា ក្នុងមួយខែត្រឹមតែ ៤ ថ្ងៃប៉ុណ្ណោះ ។ ចំណែកខាងប្រជាជនទូទៅក្នុងព្រះរាជអាណាចក្រ គួរឲ្យគណៈសង្ឃបាត់ការអប់រំតាមអគ្គការនេះ ដោយផ្លូវទេសនាៗ វិធីធ្វើគឺត្រូវរើសយកធម្មកថិក ដែលមានថ្វីមាត់ខាងវិជ្ជាផ្នែកនេះ ឲ្យនិមន្តទៅទេសនាគ្រប់ទីប្រជុំតាមអគ្គការនេះដូចគ្នា ។

ព្រះពុទ្ធសាសនាមិនមែនត្រឹមតែជាឃ្លាំងបញ្ចេញនូវសីលធម៌ ប៉ុណ្ណោះទេ ; សឹងជាឃ្លាំងបញ្ចេញនូវពាក្យពេចន៍ ដែលជាជំនួយដល់ភាសាសាស្ត្ររបស់ជាតិទៀតផង ។ មនុស្សគ្រប់ជាតិមានភាសាជាគ្រឿង

សំគាល់ ឬជាគ្រឿងបែងចែក ឲ្យហៅថាជាតិនេះជាតិនោះ ; បើយើងត្រូវការឲ្យជាតិរបស់យើង តាំងនៅគង់លោកបាន មានតែយើងត្រូវប្រញាប់ប្រញាល់រួមកំឡាំងគ្នា សាងភាសាយើង ព្រោះភាសាដែលបានសាងត្រឹមត្រូវ ហើយទាន់សម័យនោះគឺជាអាវុធមួយយ៉ាងសំខាន់របស់ជាតិ ។ ប្រទេសខ្លះក្នុងលោកនេះគេបានប្រើភាសាជាអាវុធខ្លះ ជាស្ពានខ្លះ សម្រាប់ប្រើក្នុងពេលដែលគេត្រូវការពង្រីកអំណាចខាងផ្លូវនយោបាយ ផ្លូវសេដ្ឋកិច្ច និងផ្លូវសាសនា ។ ជាតិខ្លះត្រូវគេរំលាយដោយអាវុធយ៉ាងមុត គឺភាសា និងត្រូវគេស្រូបបញ្ចូលទៅជាពលរដ្ឋរបស់គេដោយស្ពានយ៉ាងពូកែគឺភាសា ក្នុងបណ្ដាប្រទេសដែលត្រូវគេចោមរាយដោយអាវុធ គឺភាសានោះ មានប្រទេសខ្មែរយើងមួយផង ។

ក្នុងអតីតកាល ប្រមាណមិនតិចជាង ២០០ឆ្នាំ កន្លងមកនេះ, ប្រទេសខ្មែរមិនដែលបានរៀបចំសោះសូម្បីបន្តិចបន្តួច ខាងផ្នែកអក្សរសាស្ត្រ និងភាសាសាស្ត្រ; ក្បួនសម្រាប់អក្សរសាស្ត្រក្តី វណ្ណគតិក្តី ដែលជារបស់មានដំឡៃសម្រាប់ប្រទេសនោះត្រូវផុតខ្លះត្រូវរំលាយខ្លះត្រូវដឹកនាំចេញខ្លះ មានសល់នៅបន្តិចបន្តួច ក៏មិនល្មមដល់សេចក្តីត្រូវការ ។

ដល់មកឆ្នាំ ១៩១៤ រាជការបានបង្កើតឲ្យមានសាលាបាលីជាន់ខ្ពស់មួយឡើង តាំងនៅក្រុងភ្នំពេញ សាលានេះមានការសិក្សាភាសាបាលី សម្រាប់ប្រើការខាងផ្លូវពង្រីកពុទ្ធសាសនាប៉ុណ្ណោះ ។ តែជាធម្មការរបស់លោកមុននឹងប្រែភាសាដទៃមកជាភាសាជាតិរបស់ខ្លួនត្រូវតែរៀបចំភាសាជាតិ ឲ្យមានរបៀបត្រឹមត្រូវល្អជាមុនទើបអាចនឹងធ្វើបាន; ដោយមានរឿងនេះជាមូលហេតុ រាជការក៏បានចាត់ការឲ្យបង្រៀនភាសាជាតិព្រមគ្នាជាមួយនឹងភាសាបាលី តាំងពីត្រឹមនោះមក ។ ក្នុងបច្ចុប្បន្ននេះ ភាសាជាតិឃើញថាបានចំរើនជាងមុនបន្តិចដែរ ។ ប៉ុន្តែសេចក្តីចំរើនត្រឹមប៉ុណ្ណោះនេះបើយកទៅធៀបនឹងភាសាជាតិខ្លះក្នុងលោកនេះដែលរាប់ថាជាជាតិចំរើនហើយដោយភាសានោះ, ភាសាយើងនៅមិនទាន់បានភាគ ១ ក្នុងភាគរយនៃភាសារបស់ជាតិទាំងនោះនៅឡើយទេ ។

ដើម្បីនឹងដោះស្រាយបញ្ហាភាសារបស់ជាតិក្នុងរយៈវេលាឆាប់ៗនេះរាជការមុខក្រសួងនិងពុទ្ធសាសនិកជនទាំងឡាយ គួរចាត់សាងអង្គការមួយឡើងឲ្យឈ្មោះថា "អង្គការសិក្សាជំនួយភាសាជាតិ" ក្នុងអង្គការនេះ គួរចាត់ឲ្យមានកម្មវិធីបង្រៀនភាសាជាតិបញ្ចូលជាមួយនឹងភាសាបាលីក្នុងថ្នាក់រៀននៃសាលាបាលីជាន់ខ្ពស់សព្វថ្ងៃនេះ ដើម្បីឲ្យអ្នករៀនចេះតែងពាក្យពេចន៍ ពាក្យកាព្យបទឃ្លោង វេយ្យាករណ៍ខ្មែរជាដើម ឲ្យបានម៉ត់ចត់ពេញលក្ខណៈតាមរបៀបអក្សរសាស្ត្រទៅ ។

រឿងនេះយើងខ្ញុំសូមជូនយោបល់នេះចំពោះរដ្ឋាភិបាលនិងប្រជាជនកម្ពុជាថា តើគួរអនុវត្តទៅប៉ុនប្តូទេ ចំពោះអង្គការដែលរៀបរាប់មកនេះ ព្រោះជាឧត្តមប្រយោជន៍របស់ជាតិដោយពិតប្រាកដ ។

ភ្នំពេញ, ថ្ងៃ ៥ កុម្ភៈ ឆ្នាំ ១៩៥៨

ពុទ្ធបុត្ត

## ពត៌មានគួរដឹងខ្លះ គួរគិតខ្លះ

ដំណឹងពីទីភ្នាក់ងាររយទែរ បញ្ជាក់ថាកាលពីថ្ងៃទី ៣ កុម្ភៈ -៥៨ ប្រធានាធិបតី អែសិនហូវ័រ ថ្លែងក្នុងទីប្រជុំអ្នកកាសែតនៅវ៉ាស៊ិនតោនថា: ស្ថានការណ៍នៅឥណ្ឌូចិនពីបាកនឹងថា ស្រួល ឬ មិនស្រួលពេកណាស់ៗ លោកថាឥណ្ឌូចិននឹងបាត់ជម្ងឺ ឬ ជម្ងឺនឹងធ្ងន់ទៅទៀត អាស្រ័យនៅលើទឹកចិត្តប្រជាករនៃឥណ្ឌូចិនទាំងមូល ។ បើប្រជាករនៅឥណ្ឌូចិនប្រាថ្នាចង់បានសេរីភាពហើយជឿជាក់ថា ការតស៊ូនឹងកុម្មុយនិស្តអាចឲ្យខ្លួនបានគប់ប្រទេះនឹងសេរីភាពបានមែន មុខជាផលដែលហុចឲ្យចុងក្រោយបំផុត គឺជ័យជំនះដ៏ពិតប្រាកដ ។

លោកបញ្ជាក់មួយគន្លងទៀតថា វិស្វករអាមេរិកចំនួន ១២៥ នាក់ ដែលទៅនៅឯឥណ្ឌូចិន បេះតែពួ ដំណឹងថាជួយធ្វើប្រតិបត្តិការជាមួយបារាំងសេសនោះ គឺជាពាក្យពោលមិនពិតទេ, ព្រោះវិស្វករទាំងនោះនៅក្នុងឥណ្ឌូចិនគ្រាន់តែជួយបង្ហាត់បង្រៀន នឹងជាទីប្រឹក្សាបារាំងសេសឲ្យយល់វិធីប្រើយន្តហោះ ដែលអាមេរិកបានធ្វើអំណោយទៅឲ្យប៉ុណ្ណោះ ។

* *

*

វិទ្យុដេល្ហី (ប្រទេសឥណ្ឌា) ថ្លែងថាកាលពីថ្ងៃទី ៣-២-៥៨ ប្រជាជនជាង ៣ លាននាក់ បានកាត់មកពីតំបន់ផ្សេងៗ ក្នុងប្រទេសឥណ្ឌាទៅប្រជុំគ្នានៅឆ្នេរស្ទឹង ស្រុកអាល្ល:ហាបាត ត្រង់ស្ទឹងគង្គា និងស្ទឹងយមុនាប្រសព្វគ្នា ដើម្បីធ្វើពិធីលាងបាបដែលឥណ្ឌាហៅថា "ហ៊ុមមេឡា" ។ ពិធីនេះមានធ្វើក្នុងរយៈ១២ឆ្នាំម្តង គឺអ្នកទៅទាំងប៉ុន្មានបានចុះង្ងូតទឹកក្នុងស្ទឹងនោះ ឈ្មោះថាជំរះបាបឲ្យអណ្តែតទៅតាមទឹក ព្រោះគេប្រកាន់ថា ស្ទឹងនោះសក្តិសិទ្ធិណាស់ ។

វិទ្យុដេល្ហី បញ្ជាក់ថា នៅពេលចុះង្ងូតទឹកនោះ មានកើតឧបត្តិហេតុដ៏អស្ចារ្យ គឺប្រជាជនច្រើនលាននាក់នោះដណ្តើមគ្នាចុះង្ងូតដោយប្រញាប់ប្រញាល់តែរៀងខ្លួន មោះហើយមនុស្សដែលដួលត្រូវគេជាន់ស្ទើតអស់ ក្នុងខណៈនោះមានស្លាប់ដល់ ៣៥០ នាក់ និងមានរបួសជាង ១០០០ នាក់ ។ វិទ្យុនេះបានបញ្ជាក់តមកទៀតថា ចំនួនមនុស្សស្លាប់ប្រហែលជាច្រើនទៅទៀត ព្រោះមានហូរទៅតាមទឹកផង ។ ចំនួនអ្នកស្លាប់គេឃើញមានស្ត្រីច្រើនជាងបុរស ។

លោកយោវៈហាឡាល នេហ៊្រូ នាយករដ្ឋមន្ត្រី បានតាំងគណៈកម្មការឲ្យពិនិត្យអង្កេតរឿងនេះ

រហើយការពារកុំឲ្យមានកើតឧបត្តិហេតុទៀត ព្រមទាំងបានសរសើរក្រុមប៉ូលិសនៅអាល្វះហាបត្ត ថាប៉ុនប៉ោក្នុងការជួយសង្គ្រោះអ្នករងទុក្ខផង ។

វិទ្យុផ្សាយ ថ្ងៃបន្ទាប់មកទៀតថា លោកនេហ៍រុ បានបញ្ជាក់ថា ចំនួនអ្នកបាត់បង់ជីវិតទាំងអស់មានលើសពី ៣៥០ នាក់ ចំណែកអ្នករបួសជាង ៣០០០ នាក់ ។ ខ្លួនលោកនេហ៍រុផ្ទាល់នៅទីនោះដែរ បានជួយអ្នករងគ្រោះយ៉ាងខាន់ហាន់ផង លោកមានប្រសាសន៍ថាបានជាកើតអន្តរាយច្រើនម៉្លេះ ព្រោះទឹកស្ទឹងគង្គាជោរខ្ពស់ពេក នាំឲ្យច្រាំងរអិល ធ្វើឲ្យអ្នកនៅមុខដួលហើយអ្នកក្រោយសង្កត់ ។

* *
*

ដំណឹងពីនគរស៊ិគណាថា ក្នុងឱកាសដែលសម្តេចព្រះមហាក្សត្រីអេលិសាបេធ នឹងព្រះស្វាមីបានស្តេចប្រពាស ទូទៅតាមប្រទេសដែលរួមក្នុងចក្រភពអង់គ្លេសនោះ ព្រះមហាក្សត្រីបានយាងចូលទៅក្រុងស៊ិគណាហើយ, ព្រះអង្គនឹងស្តេចប្រថាប់អស់កាល ១ខែនៅទីនេះ ។

ក្នុងឱកាសទទួលនោះ រាជការអូស្ត្រាលី បានចាត់នាវាចម្បាំង, នាវាផ្ទុកយន្តហោះឲ្យទៅហែហមពីកណ្តាលសមុទ្រមកចម្ងាយផ្លូវចំនួន ១១០០ គ.ម. ដោយមានបាញ់កាំភ្លើងថ្វាយ ២១ណាត់ផង ។ មានដំណឹងថាមានជនអកុសល ផ្ញើសំបុត្រថានឹងធ្វើគត់ព្រះនាងរាជិនី ដែលសព្វថ្ងៃនេះ ប៉ូលិសរកចាប់មុននាក់បានថ្វាយអារក្សាយ៉ាងពេញទី ។

* *
*

នៅពេលថ្មីៗនេះការប្រជុំ ៤ មហាអំណាចនៅប៊ែរឡាំង បានសំរេចឲ្យប្រជុំពួកប្រទេសនៅអាស៊ីអាគ្នេយ៍ខ្លះនៅហ្សឺណែវ ដើម្បីដោះស្រាយបញ្ហាឥណ្ឌូចិននឹងកូរ៉េ ។ ប្រហែលជានឹងមានធ្វើនៅថ្ងៃទី ២៦ មេសានេះហើយ ។

* *
*

អំពីវៀតមិញវាយលាវ ដើម្បីទំលាយក្រុងហ្លួងព្រះបាងនោះឮថាបេះតែវាយគោបយ៉ាងសម្បើម ។ តាមដំណឹងពីបាងកកថា នៅប្រទេសលាវខាងជើងវៀតមិញមានទ័ពប្រហែល ១២.០០០នាក់ ប៉ែកខាងជៀនបៀនហ្វូ ចូលមកវាយលាវកណ្តាល មានទ័ពប្រហែល ២០.០០០ នាក់ ។

* *
*

ដំណឹងពីតូក្យូថា ប្រធានបរិស័ទអាកាសយានជប៉ុនឈ្មោះ ហ្វូប៉ុង អែរឡៃន៍ ថ្លែងថា យន្តហោះរត់ឈ្នួលរវាងជប៉ុន នឹងអាមេរិក ត្រូវដំឡើងមួយខ្សែទៀត ដោយហោះកាត់អាឡាស្កា ។ ចំណែកយន្តហោះរត់ឈ្នួលរវាងជប៉ុន - អង់គ្លេស នឹងហោះកាត់ហុងកុង, រ៉ង់គូន, កាល់កុត្តា, ការ៉ាជី, ក្រុងនែរ ៗ បរិ-

ស័ព្ទនេះនឹងប្រើយន្តហោះប្រតិកម្មយីហោ "តូរម៉ែត" ដែលទិញពីអង់គ្លេស ។

* *
*

ដំណឹងពីទីក្រុងតេហេរ៉ង់ថា ក្នុងការបោះឆ្នោតជ្រើសរើសបេក្ខជនជាសមាជិកសភាជាន់ខ្ពស់ អ៊ីរ៉ង់ មានកើតចលាចលហេតុតែពួកបក្សកុម្មុយនិស្ត និងពួកលោកម៉ូស្សាដេក្រ ហើយនឹងក្អាក់ការប៉ូលិស ៗ មានគេចាប់បាន៣០នាក់ ។

ការបោះឆ្នោតនេះ អស់បីរវេលា ៣ថ្ងៃទើបចប់ៗ

មានរឿងដំណាលថា អតីតនាយករដ្ឋមន្ត្រីម៉ូស្សា-ដេក្រសូម្បីអស់សិទ្ធិ ជ្រើសតាំងនឹងគេក៏ដោយ ក៏នៅមានមនុស្សយកឈ្មោះបក្សពួកលោកនេះ ចំនួន ៧៥ នាក់បញ្ចូលក្នុងបញ្ជីបោះឆ្នោតយ៉ាងស្ងាត់ៗដែរ ។ មាននិស្សិតមហាវិទ្យាល័យនឹងមធ្យមសិក្សា បានធ្វើបាតុកម្មពេញក្រុងអំពាវនាវសុំបោះឆ្នោតឲ្យ ម៉ូស្សា-ដេក្រ ។

* *
*

នៅប្រទេសជប៉ុន ភ្នំភ្លើងឈ្មោះអាសាម៉ាដែលតាំងនៅខាងជើងក្រុងតូក្យូ ១៤៤ គ.ម. កើតផ្ទុះយ៉ាងខ្លាំង ៗ បានព្រួសធូលីនឹងដុំថ្មផ្សែងទៅលើអាកាសកំពស់៦.០០០ហ្វីត (មួយហ្វីតមួយជំហាន) ភ្នំភ្លើងនេះតាំងនៅជិតស្រុកមួយសំរាប់ជាទីសញ្ចរ នៃមនុស្សដែលទៅយកខ្យល់អាកាស ឈ្មោះស្រុក ការុសាវ៉ា ៗ

* *
*

កាលពីថ្ងៃទី ៥ កុម្ភៈ រដ្ឋមន្ត្រីបារាំងបានបញ្ចេញមតិព្រមព្រៀង ឲ្យអ្នករាជការតូចតាចឡើងបៀវត្សរ៍ឲ្យបានខ្ពស់ជាងដើម ។

## ការប្រជុំពេលប្រាស្រ័យសមាគមមិត្តសាលាបាលី និងពួកសិស្សចាស់នៃសាលាបាលីជាន់ខ្ពស់ ។



កាលពីថ្ងៃសៅរ៍ទី៦កុម្ភៈ ១៩៥៤, មានការប្រាស្រ័យរាក់ទាក់សមាគមមិត្តសាលាបាលី និងពួកសិស្សចាស់ នៃសាលាបាលីជាន់ខ្ពស់នៅវត្តលង្កា ក្រុងភ្នំពេញ ។

ម៉ោង១៧, លោកក៉យ-ប៊ុក អធិបតីសមាគមមិត្តសាលាបាលីបានថ្លែងសុន្ទរកថាមួយ បើកសម័យប្រជុំពណ៌នាអំពីសកម្មភាព, សម្ភារៈនិងសីលធម៌នៃសមាគម, លទ្ធផលដែលបានពីសកម្មភាពនេះ; ហើយបានអំពាវនាវឲ្យសិស្សានុសិស្សទាំងអស់ ចូលមករួបរួមនឹងសមាគមដោយសាមគ្គីធម៌ដ៏ឧត្តម ។



ព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់បានមានព្រះពុទ្ធដីការៀបរាប់ ការស្ថាបនាកម្មវិធីសិក្សានៃសាលាបាលីជាន់ខ្ពស់ ព្រមទាំងមហាវិទ្យាល័យព្រះសង្ឃដែលកំពុងកសាង នឹងការសិក្សាជាដើម ។



ព្រះអរិយកស្សប អ៊ុច. ប្រតិភូសម្តេចព្រះសុធម្មា

ធិបតីអ៊ុង-ស្រី សង្ឃនាយក គណៈធម្មយុត្តិ មានព្រះពុទ្ធដីកាដាស់តឿន ក្រើនរំឭកដល់ពួកសិស្សចាស់ ដែលអញ្ជើញមកក្នុងទីសន្និបាតនោះឲ្យជួយឧបត្ថម្ភសមាគមមិត្តសាលាបាលី ដោយលោកបានពោលបញ្ជាក់ថា: “ប្រៀបដូចជាព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គទ្រង់សោយវិមុត្តិរស ក្រោមមហាពោធិ–ព្រឹក្សគ្រប់ ៧ ថ្ងៃ, ទ្រង់យាងចុះពីរតនបល្ល័ង្ក ហើយព្រះអង្គឈៀងព្រះនេត្រ ទៅរកគល់ពោធិព្រឹក្សវិញ ដើម្បីសងគុណទូវគល់ពោធិនោះ, យ៉ាងណាមិញ លោកអ្នកទាំងឡាយមានជោគវាសនាដ៏ល្អ ក៏ដោយសារគុណសាលាបាលីជាន់ខ្ពស់ ជាកន្លែងផ្សាំពូជឲ្យដុះដាលចម្រើនឡើង. គួរលោកអ្នកគប្បីសងគុណកុំខាន...” ។



ឯកឧត្តមសម-ញាណរដ្ឋមន្ត្រីក្រសួងធម្មការបានពណ៌នាអំពីព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា, .មធ្យោបាយ ដែលនឹងធ្វើឲ្យចម្រើន, សាលាបាលីជាន់ខ្ពស់, មហាវិទ្យាល័យព្រះសង្ឃ, ការបំរើនខាងព្រះពុទ្ធសាសនា ដោយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង

ទ្រង់ជាពុទ្ធសាសនូបត្ថម្ភក; ក្នុងទីបញ្ចប់សុន្ទរកថា ឯកឧត្ដមបាន សូមឲ្យលោក-អ្នកទាំងអស់ ព្រួតដៃគ្នាទ្រទ្រង់សាលាបាលីជាន់ខ្ពស់ ព្រមទាំងសមាគមមិត្តសាលាបាលីកសាងព្រះពុទ្ធសាសនាព្រមទាំងវឌ្ឍនធម៌ប្រទេសឲ្យមានដំណើរស្របគ្នាទៅអនាគត.... ។

ការប្រជុំនេះបានបញ្ចប់នៅម៉ោង ១៨, ក្រោយដែលពួកសិស្សចាស់នៃសាលាបាលីជាន់ខ្ពស់ បានមកសូមចុះ ជាសមាជិកនៃសមាគមនេះ ទើបជាទស្សនាវដ្ដី"មិត្តសាលាបាលី" ។

យោបល់ទស្សនាវដ្ដី "មិត្តសាលាបាលី" ការដែលសិស្សានុសិស្សសាលាបាលីជាន់ខ្ពស់ទាំងបព្វជិតនិងគ្រហស្ថ បានចូលមករួបរួមដោយសាមគ្គីធម៌ដ៏មុះមុតក្នុងសមាគមមិត្តសាលាបាលីនេះ ទុកជាការធំមួយដ៏វិសេសសម្រាប់កាត់ឆ្ការនូវឧបសគ្គគ្រប់យ៉ាង ការទំនុកបម្រុងសាលាបាលីជាន់ខ្ពស់ និងសាលាបាលីរងក៏បានចម្រើនក្នុងព្រះរាជាណាចក្រ អាចធ្វើដំណើរឲ្យបានសុខស្រួល ។ ជនអ្នកស្ដាប់ឱវាទ ក្រុមសិស្សានុសិស្សដែលនិមន្តទៅទេសនាក្នុងព្រះរាជធានី, គ្រប់ខេត្ត, និគម, ជនបទ, ឬដែលបានអញ្ជើញទៅធ្វើជាមន្ត្រីតាមក្រសួង, តាមក្រុម, ខេត្ត, ស្រុក, ឃុំ, ពន្យល់បំភ្លឺអំពីគតិលោក, គតិធម៌ ដែលជាគតិនាំឲ្យព្រះពុទ្ធសាសនានិងជាតិឲ្យចំរើននេះហៅថា "មិត្តសាលាបាលី" ។ បើមិត្តនេះបានចូលមកក្នុងសង្គមយើង, ប្រៀបដូចជា "ការពេញក្លួបជាខ្សែនៃសរសៃអម្បោះអាចយកទៅចងដំរីបាន" នោះជាការប្រសើរណាស់ទៅទៀត ព្រោះថា កំឡាំងមួយសម្រាប់គាំទ្រព្រះបរមមហាក្សត្រិយ៍ជាទីស្រឡាញ់ពេញចិត្តរបស់យើងក្នុងការកសាងប្រទេសកម្ពុជាឲ្យបានឯករាជ្យដោយសម្បូរណ៍ ។

បើព្រះសង្ឃ និងគ្រហស្ថ ដែលបានសិក្សារៀនសូត្រនៅសាលាបាលីរងគ្រប់ខេត្តក្នុងព្រះរាជាណាចក្របានចូលមកប្រាស្រ័យ និងសមាគម ក៏ជាម្ហូបមួយធំសម្រាប់ឲ្យកូនយើងទាំងឡាយ ចូលមកពឹងពាក់អាស្រ័យបានត្រជាក់កាយសប្បាយចិត្តគ្រប់ៗ គ្នា ដូចជាផ្កាកុលាបរីកក្រហមព្រាលឆ្អៅ ក្រោមកំដៅព្រះសុរិយាទិនបុព្វណ្ហសម័យ គួរឲ្យមានហសនចិត្ត ប្រកបដោយបីតិ, បាមោជ្ជៈ យ៉ាងណាទៅ? នេះហើយដែលសមាគមមានបំណងជាអវសាន ។ បើសេចក្ដីរួបរួមទាំងអស់ចូលទៅស្ថិតនៅក្នុងសន្ដានចិត្តសិស្សានុសិស្សនិងមិត្តសាលាបាលី. ដែលស្គាល់ពិតនូវប្រយោជន៍ក្នុងសាមគ្គីធម៌ដ៏ឧត្ដម, ដែលយល់ច្បាស់នូវប្រយោជន៍ជាសាធារណៈ,ជាតិមាតុភូមិ,ព្រះពុទ្ធសាសនា ព្រះមហាក្សត្រិយ៍តើចិត្តក្រុមអភិបាលសមាគម. ឬ ដួងវិញ្ញាណសមាគមនឹងក្រេបនូវអត្ថរសដ៏ប្រសើរសុខស្រួលសមទៅតាមបំណង ដូច (ជាបុរសឃើញស្ត្រីជាទីពេញចិត្ត) យ៉ាងណាទៅ?

ព្រះតេជព្រះគុណ, លោកអ្នកទាំងឡាយ,

សូមលោកអ្នកក្រឡេកមើល ទៅសាលាបាលីជាន់ខ្ពស់ ដែលមានចង់សមាគមមិត្តសាលាបាលី

ដោតនៅលើដំបូលជាប្រធាន, ហើយសូមឲ្យត្រាប់តាមសាលា ឬទង់នោះ,

លោក-អ្នកនឹងបានឃើញជោគជ័យដ៏វិសេសក្នុងកាលជាអនាគតមិនខាន :

សិស្សានុ- សិស្សសាលា បាលីពិត
រួបរួមគ្នា សាមគ្គីមិត្ត ចិត្តព្រមព្រៀង
ចូលសមា- គមសាលា- បាលីទៀង
ត្រូវតែផ្ញើ ល្បីសូរសៀង ជោគជ័យអើយ ។

---

## វគ្គទី ៤

## អក្សរសាស្ត្រខ្មែរ

(តពីទស្សនាវដ្តីមិត្តសាលាបាលី
លេខ ១០-១១-១២ ឆ្នាំ ១៩៥២)

### ១– បុព្វហេតុ

អក្សរសាស្ត្ររបស់ប្រទេសកម្ពុជា មានតាំងពីបុរាណកាលមក, ក្នុងសតវត្សទី ៧ គេបានរកឃើញសិលាចារិក ជាអក្សរជាតិនៅភាគខាងត្បូង ដែលមានលក្ខណៈរុងរឿងជាច្រើនបែប គឺៈ ប្រវត្តិសាស្ត្រ, សាសនា, រឿងល្ខោន, ពាក្យកាព្យឃ្លោង, រឿងព្រះលោមលោក, អក្សរសាស្ត្រតិកទិក, រឿងព្រេង, សុភាសិត, ចម្រៀងបុរាណ ។ល។

បុព្វហេតុនៃអក្សរសាស្ត្រខ្មែរ យើងមិនអាចនឹងស្រាវជ្រាវឃើញដោយសព្វគ្រប់បានទេ, ប៉ុន្តែយើងអាចដឹងបានថា មានអក្សរសាស្ត្រទាក់ទងនឹងមន ដោយខ្មែរនឹងមនភ្ជាប់ប្រាស្រ័យគ្នា ។ តាមសៀវភៅភាសាខ្មែរ(ក្បាលទី១)របស់លោក អៀវ-កើស អតីតប្រធានរដ្ឋសភាថា: "ក្នុងអម្បូរនេះមានខ្មែរ-មន ហើយនឹងជាតិព្រៃដូចជា" បាឡូងនៅជាប់នឹងមន, "រៀងនឹងកា" នៅត្រើយខាងកើតទន្លេសាល្វិន ប៉ែកខាងជើងប្រទេសសៀម, "ធិន" នៅប្រទេសសៀមភាគខាងជើង, "ឃ្មុ ឬ ឃ្មូ" នៅខាងល្អងព្រះបាងនឹងវៀងច័ន្ទ ហើយនឹងពរ, ផង, កួយ, ស្អៀង, គួង...នៅក្នុងប្រទេសខ្មែរ ។

ភាសាទាំងនេះស្រដៀងគ្នា ដោយលក្ខណៈទាំង ៣ គឺទាំងសូរសាស្ត្រ, រូបសាស្ត្រនឹងវិយណ្ណសាស្ត្រ ។ ក្នុងអម្បូរមន-ខ្មែរ, មានតែមននឹងខ្មែរនេះទេដែលមានអក្សរសាស្ត្រប្រើ ។ ក្នុងបណ្ដាជាតិទាំង ២ នេះ, ឃើញថាមានប្រជាជាតិ ( Nation ) នៅគង់ទ្រង់ជាប់ដល់សព្វថ្ងៃមានតែខ្មែរមួយទេ, ចំណែកមនត្រូវលាយជាតិបាត់តាំងពីក្នុងរវាងចុងសតវត្សទី ១៣ ម្ល៉េះ ដោយការបៀតបៀនរបស់ភូមានឹងសៀម ។

បើតាមសេចក្ដីស្រាវជ្រាវរបស់អ្នកប្រាជ្ញអក្សរសាស្ត្រខាងបច្ចិមប្រទេស ចំពោះអក្សរសាស្ត្រខ្មែរ ឃើញមានដំណើរដូចតទៅនេះ

១– លោកបាស្ទីយាង ( Bastian ) - ក្នុងសៀវភៅ " Reise durch Kambodja " ដែលបានចារិកទុកក្នុង " Journal asiatique " ឆ្នាំ ១៨៧៨ - ទំព័រ ៣៤៨ ថា " រឿងព្រេងផ្សេងៗ ដែលមាននៅប្រទេសកម្ពុជា សុទ្ធតែដកស្រង់មកពី

អក្សរសាស្ត្រសៀម" ។

២ – លោក ឡេអុងហ្វែរ (Léon Feer) – ក្នុងសៀវភៅ " Etudes cambodgiennes " ដកស្រង់ចេញពីទស្សនាវដ្ដី "Journal Asiatique" ផ្នែក ៧ - ភាគ ៩ - ទំព័រ ១៨២ ថា: " តាំងពីបុរាណសម័យមក, ប្រទេសសៀម បានអប់រំអក្សរសាស្ត្រជាតិរបស់ខ្លួន ដោយខ្ចីរូបអក្សរខាងអក្សរសាស្ត្រខ្មែរ ហើយចំណែកអក្សរទទឹងសៀវភៅបកប្រែ មិនមែនសុទ្ធតែជាភាសាខ្មែរឬសៀមទេ គឺភាសាឥណ្ឌូចិនទាំងមូល; អក្សរសាស្ត្រខ្មែរ មិនមែនជាគ្មានបុព្វហេតុពិតប្រាកដនោះទេ, បើតាមសង្កេតមើលដោយម៉ត់ចត់ទៅ គេឃើញមានហេតុទាក់ទងមកពីអក្សរសាស្ត្រឥណ្ឌា..... អក្សរសាស្ត្រប្រលោមលោកច្រើនមានសភាពជាសេរីជាងអក្សរសាស្ត្រទាំងអស់, តែច្រើនកំណត់យកកមត៍, គោលការ, សញ្ញាណគ្រប់បែបដែលចួនកាលដកស្រង់ពីរឿងពិតឬរឿងព្រេងរឿងសាសនា ។

៣ – លោកអាដេហេម៉ារឡេក្លែរ (Adhémar Leclère) បានពោលក្នុងសៀវភៅ " រឿងល្ខោនខ្មែរ " ដែលដកស្រង់ពីទស្សនាវដ្ដី " ទំនៀមទំលាប់ទំនងសង្គម " ឆ្នាំ ១៩១០-ទំព័រ២-៦ ថា: អក្សរសាស្ត្រសៀម បានដកស្រង់យកពីអក្សរសាស្ត្រខ្មែរជាច្រើនកន្លែង...។

៤ – លោកតូប៉ាំង (J. Taupin) – ក្នុងសៀវភៅ "ការពិនិត្យចំពោះអក្សរសាស្ត្រខ្មែរ" ដែលបានសរសេរក្នុងប៊ុល្លីតាំងនៃសមាគមសិក្សាឥណ្ឌូចិន ឆ្នាំ ១៨៨៦ - ឆមាសទី ១ ទំព័រ ២៣ – ៤៧ មានសេចក្ដីថា ភាសានិងអក្សរសាស្ត្រខ្មែរ មានន័យដកស្រង់មកពីអក្សរសាស្ត្រសំស្ក្រឹត ។

២– សមាសភាព

តាមសិលាចារឹកនៅប្រាសាទបុរាណទាំងឡាយ មានអក្សរជាដើម ដែលអ្នកប្រាជ្ញខាងបុរាណវត្ថុ មានលោកសឺដែស, ម៉ាសាល់, ឡេវីនិងលោកឈឺមគ្រែសម ជាដើម បានស្រាវជ្រាវរកតាំងពីដំបូងមក ឃើញថាអក្សរសាស្ត្រខ្មែរមានមកយូរយារណាស់ហើយ ។ ក្នុងអក្សរ " សារណានៃប្រពៃណីប្រទេសកម្ពុជា " ដែលលោក ជូ-តា-ក្វន អ្នកដំណើរចិន បានចារិកទុក ហើយដែលលោក ប៉ុល-ពេល្លីយ៉ូត ជាសាស្ត្រាចារ្យវិជ្ជាស្ថានបារាំងនៅចុងបូព៌ាប្រទេស បានបកប្រែមកនោះថា " អក្សរខ្មែរក្នុងសម័យនោះ មានអក្សរប្រើតាមផ្លូវការជាដើម ច្រើនសរសេរលើផ្ទាំងស្បែកឈ្លូស ឬ ប្រើសលាបពណ៌ខ្មៅ. ស្បែកនោះតូចក៏មានធំក៏មានដែលគេធ្វើតាមសេចក្ដីពេញចិត្តរបស់ខ្លួន ។ ប្រជាជនប្រើម្សៅសម្រាប់សរសេរដូចជាដីសនៅប្រទេសចិន ។ គេអាចយកដីសនោះមកសរសេរអក្សរមិនរលុបបាន, កាលបើសរសេររួចហើយ គេសៀតដីសនោះនៅកៀន

ត្រៀត ៗ អក្សរដែលសរសេរហើយគេរាប់ស្គាល់ ដល់រូបអក្សរសរសេរផ្សេងទៀត ៗ លុះត្រាតែយកវត្ថុទទឹកសើមទៅជូតទើបអក្សរនោះលេចបាន ៗ អក្សរខ្វះដូចគ្នានឹងអក្សរអ៊ុយគួរស់ (Ouigours, houei, hou) គេសរសេរពីឆ្វេងទៅស្តាំ, មិនមែនពីលើមកក្រោមទេ ៗ ខ្ញុំបានឮគេនិយាយថានៅ យេ-សៀនហៃយ៉ា (Ye-Xien-Hai-Ya ជាស្បូវស័ព្ទអក្សរនោះដូចគ្នានឹងអក្សរជាតិមុងហ្គោល, មានរូបគ្នាតែអក្សរ តីរ-ប៉ប៉ុរណ្ណា: ៗ

តាមសិលាចារឹកដែលបានរកឃើញ នៅជាន់ម៉ោយ (គូសាំងស៊ុន) គង់រាជ្យសតវត្សទី ៧, អក្សរសាស្ត្រខ្មែរក្នុងពេលនោះ មានច្រើនបែប ហើយអក្ខរពន្ធច្រើនតែងរៀងរាល់ដែលជាប់ទាក់ទង ដោយប្រវត្តិសាស្ត្រនឹងសាសនាជាមូលដ្ឋាន ៗ អក្សរសាស្ត្រខ្មែរចែកចេញជា ៤ យុគៈគឺ ៖

យុគៈ ទី ១– ចាប់តាំងពីបឋមកាលដរាបមកដល់សតវត្ស ទី៧, អក្សរសាស្ត្រខ្មែរមាន២ យ៉ាង:

ក) អក្សរដែលសរសេរទឹងជ័រលើស្បែកខ្លា;

ខ) អក្សរដែលសរសេរចារឹកទុក

ក៉ុយ_ប៊ុក

(នៅមានត)

## មហាសន្និបាត សមាគមគិលានសង្គ្រោះបំពោះព្រះសង្ឃ ពុទ្ធសាសនិកនៅភូមិទឹកល្អក់

ភ្នំពេញ– ដូចយើងបានដំណឹងមកហើយ, កាលពីថ្ងៃទី ២០មករា១៩៥៤នេះ ពេលម៉ោង១៥នៅក្នុងកសាងមន្ទីរពេទ្យព្រះសង្ឃពុទ្ធសាសនិក ដែលតាំងនៅត្រង់ភូមិទឹកល្អក់ ភ្នំពេញ មានធ្វើពិធីប្រជុំមហាសន្និបាតនៃសមាគមគិលានសង្គ្រោះ បំពោះព្រះសង្ឃពុទ្ធសាសនិក ក្រោមអធិបតីភាពនៃឯកឧត្តម ឃួន-ណៃ ជាប្រធាននៃសមាគមនេះ ៗ

ក្នុងចំណោមឥស្សរជនដែលបានទៅជួបជុំនៅពេលនោះ គេសង្កេតឃើញឯកឧត្តម សម-ញ៉ាណ រដ្ឋមន្ត្រីក្រសួងធម្មការ, ឯកឧត្តម អ៊ុក-ជុប ប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ, លោកក៉យ.ប៊ុក អធិបតីសមាគមមិត្តសាលាបាលី, លោកប្រាសាណស. គាន់សកុល ប្រតិភូនៃពុទ្ធសមាគមថៃ ហើយនឹងអ្នកមុខអ្នកការដទៃទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយពុំបានចេញនាមឲ្យសព្វគ្រប់ ៗ

ក្នុងចំណោមព្រះសង្ឃ ៤០០អង្គ ដាំងក្នុងទីក្រុងនិងខេត្តក្រៅ ដែលនិមន្តទៅជាកិត្តិយសៈនាពេលនោះ គេសង្កេតឃើញ សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ, ព្រះមង្គលទេពាចារ្យគួង គណៈសម្តេចព្រះសុធម្មាធិបតីសង្ឃនាយក

គណៈធម្មយុត្តិ, ព្រះតេជព្រះគុណព្រះពោធិវង្ស ហួត-តាត ចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងមន្ត្រីសង្ឃទាំងអស់ក្នុងព្រះរាជាណាចក្រ ។

មុនដំបូង, ឯកឧត្តម ឃួន-ណៃ បានថ្លែងសុន្ទរកថាមួយ មានសេចក្តីដូចតទៅនេះ ៖

សម្តេច,

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ,

ឯកឧត្តម,

លោក-អ្នកសប្បុរសទាំងឡាយ,

កាលមហាសន្និបាតឆ្នាំទៅនៅថ្ងៃទី ២២ ខែកុម្ភៈ គ.ស.១៩៥៣ ខ្ញុំព្រះករុណាបានពិតពណ៌នាដោយសង្ខេប នូវស្ថានការណ៍នៃសមាគម ចាប់តាំងពីថ្ងៃកំណើត គឺថ្ងៃទី២៨ខែធ្នូ គ.ស. ១៩៤៩ មកទល់នឹងចុងឆ្នាំ ១៩៥១ ហើយបានរៀបរាប់ដោយល្អិត នូវកិច្ចការទាំងឡាយដែលបានធ្វើក្នុងឆ្នាំ ១៩៥២ ។

នៅទីអវសាន បានទូលថា ឧបសគ្គទាំងឡាយដែលនាំឲ្យយឺតដំណើរប្រហែលជាផុតអស់ហើយ, អំណើសទៅមុខក្នុងឆ្នាំ ១៩៥៣ នេះ មានតែកិច្ចមួយទេ ដែលសំខាន់ជាងគេគឺការរកប្រាក់ឲ្យបានគ្រប់គ្រាន់នឹងចំណាយឲ្យទាន់ការសង់គេហដ្ឋានមួយយ៉ាងធំ សម្រាប់ប្រគេនភិក្ខុ-សាមណេរ មានអាពាធបួលសឹងប៉ុណ្ណោះ៖ ការត្រួតត្រាមើលខុសត្រូវក្នុងកិច្ចការសង់ជាតិកទិកនោះ ក្រសួងសាធារណការគេទទួលធ្វើឲ្យទាំងអស់ ។

ព្រះតេជព្រះគុណ,

ក្រោយមហាសន្និបាត គណៈកម្មាធិការនាយកថ្មីក៏យកចិត្តទុកដាក់ខ្នះខ្នែងបំពេញកិច្ចរៀងខ្លួន ។

បានចាប់សង់បង្ហើយរោងប្រក់ស័ង្កសីដែលអាក់ខានដោយមានឧបត្តិហេតុកំរាកពីថ្ងៃមុន, រួចក៏បានចាក់ដីក្នុងរោងនោះ និងជុំវិញទីកន្លែងដែលត្រូវសង់មន្ទីរពេទ្យឲ្យផុតពីទឹកលិច, បានចំនួនជាង ៣៨០០ ម៉ែត្រគូប ។ អ្នកម៉ៅការក៏ចាប់សង់គ្រឹះស្ថានដែលកំពុងធ្វើសព្វថ្ងៃ ពីថ្ងៃទី២១ខែមីនា គ.ស. ១៩៥៣ ។ គេបានចាត់ចែងប្រុងប្រៀបការតាមធម្មតារបស់អ្នកធ្វើការធំ គឺបានទិញស៊ីម៉ង់ត៍ច្រើនពាន់បាវមកគរទុកក្នុងឃ្លាំង, ទិញដែកផ្ទាល់ពីប្រទេសបារាំងតាមចំនួនដែលត្រូវការ, និងប្រដាប់ប្រដាឯទៀតមានគ្រួសខ្សាច់ជាដើម ។

ដំណើរការក៏បានដើរស្រួលរហូតមកដល់សព្វថ្ងៃនេះ ។

ចំណែកខាងការរកប្រាក់វិញ មានសេចក្តីលំបាកច្រើនប្រការមកពាំងមិនឲ្យមានដំណើរលឿនទៅបានតាមបំណង ។

ការលំបាកទីមួយ, មកពីមុខការនេះប្រៀបបីដូចជារុក្ខជាតិដែលធ្លាប់កើតនៅស្រុកត្រជាក់ ហើយយកមកបណ្តុះនៅស្រុកក្តៅ មានការលំបាកនឹងបណ្តុះយ៉ាងណា? បើជាដុះហើយមានការលំបាកនឹងថែទាំ

ឲ្យមានជីវិតរស់នៅយ៉ាងណា? មុខការដែលបង្កើតនេះក៏មានសេចក្ដីលំបាកយ៉ាងនោះដែរ ។

បើប្រសិនជាក្រឡេកមើលទៅខាងអតីតកាលវិញ នឹងឃើញថាអគ្គការលំបាកនេះមានតាំងពីដើមរៀងមក, គិតតាំងពីសម័យព្រះពុទ្ធអង្គគង់ធរមាននៅឡើយ រហូតមកដល់បច្ចុប្បន្ននេះ ព.ស.កន្លងទៅហើយបាន ២៤៩៦ វស្សា, មានតំណាលថា មានកើតមន្ទីរពេទ្យសំរាប់ព្យាបាលរោគចំពោះបព្វជិតដោយឡែកតែ ៤ លើកទេ,

លើកដំបូង ក្នុងសម័យព្រះពុទ្ធអង្គគង់ធរមាននៅឡើយមានព្រះមហាក្សត្រមួយព្រះអង្គ ព្រះនាមព្រះបាទពិម្ពិសាររាជ សោយរាជ្យក្នុងក្រុងរាជគ្រឹះដែនមគធៈ បានកសាងមន្ទីរពេទ្យ សម្រាប់ព្រះសង្ឃសាវ័កនៃព្រះសម្មាសម្ពុទ្ធដាច់ដោយឡែក ឲ្យឈ្មោះថា "គិលានសាលា" ។

លើកទី ២ ក្រោយព្រះសម្មាសម្ពុទ្ធបរិនិព្វាន ២១៨ វស្សាទៅហើយ, ព្រះបាទធម្មាសោករាជ ឬព្រះបាទអសោកមហារាជ សោយរាជ្យក្នុងក្រុងបាតលិបុត្តក្នុងដែនមគធៈដែរ បានកសាងមន្ទីរពេទ្យមួយដោយឡែក សម្រាប់ព្យាបាលរោគព្រះសង្ឃ, មន្ទីរពេទ្យក្នុងសម័យនោះ ឲ្យឈ្មោះថា "អារោគ្យសាលា" ។

លើកទី ៣ នៅលង្កាទ្វីប ព្រះបាទទុដ្ឋគាមនីអភ័យ បានកសាងមន្ទីរពេទ្យមួយដោយឡែក សម្រាប់ព្រះសង្ឃនៅក្នុងក្រុងអនុរាធបុរី តែមិនបានចាំច្បាស់ថា សម័យនោះគេឲ្យឈ្មោះអ្វី ប៉ុន្តែគ្រឹះដំណែលនេះ សម្ដេចព្រះសង្ឃនាយក គណៈមហានិកាយ សព្វថ្ងៃបានឃើញនឹងព្រះនេត្រ ព្រះអង្គឯងកាលនិមន្តទៅបំពេញបេសកកម្មនៅប្រទេសលង្កា ។

លើកទី ៤ នៅប្រទេសកម្ពុជា ក្នុងសម័យនគរធំ មានមហាក្សត្រមួយព្រះអង្គ មានព្រះនាមលេចឮខ្ចរខ្ចាយខាងបូព៌ាប្រទេស បានកសាងមន្ទីរពេទ្យសម្រាប់ព្រះសង្ឃមួយ ឲ្យឈ្មោះថា "អារោគ្យសាលា" ដូចសម័យព្រះបាទធម្មាសោករាជដែរ, ព្រះបរមក្សត្រអង្គនេះគឺព្រះបាទជ័យវរ្ម័នទី ៧ ។

សេចក្ដីរៀបរាប់មកខាងលើនេះ ក្នុងការលំបាកទី១ចង្អុលឲ្យឃើញថា នេះជាការកម្រពេក ពុទ្ធបរិស័ទដែលជាអ្នកផ្ដើមកសាងមន្ទីរពេទ្យតាំងពីប៉ុន្មាន នៅក្នុងប្រទេសឥណ្ឌាក្ដី លង្កាទ្វីបក្ដី កម្ពុជាក្ដីសុទ្ធសឹងតែនៅក្នុងព្រះបរមរាជូបត្ថម្ភនៃព្រះបរមក្សត្រដែលមានព្រះរាជទ្រព្យច្រើនជាអនេក ព្រមទាំងមានសទ្ធាក្លៀវក្លាមុតមាំយ៉ាងអស្ចារ្យ ។

ការលំបាកទី២ ព្រោះការវិបត្តិប្រទេសយើងកើតមានអសន្តិសុខពាសពេញ ក្នុងព្រះរាជអាណាចក្រ បណ្ដាលឲ្យសេដ្ឋកិច្ចប្រទេសទន់ខ្សោយ ជាបច្ច័យឲ្យពពួកពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លាអន់ទន់ខ្សោយនូវការបរិច្ចាគទ្រព្យជាច្រើន តួយ៉ាងដូចជាលោក-អ្នក ដែលធ្លាប់បរិច្ចាគទ្រព្យជាថ្លៃ១០០រៀលពីជាន់មុន, ក្នុងសម័យនេះ ត្រឡប់ជាបរិច្ចាគបានតែ ១០ឬ

២០រៀលទៅវិញ ។

ការលំបាកទី ៣– ដម្លៃប្រាក់ប្រទេសយើងចុះថ្លៃ, បណ្ដាលឲ្យទំនិញសព្វសារពើឡើងថ្លៃជិតមួយជាពីរខ្ទះ ។ លើសមួយជាពីរផង ដូចជាដែកមូលកាលដើម១គីឡូថ្លៃជាង៥រៀល ឥឡូវនេះ ឡើងថ្លៃជាង៨រៀលក្នុង១គីឡូ, ស៊ីម៉ងត៍កាលដើមថ្លៃ ៥២ រៀល ឥឡូវនេះ ឡើងជា១០០រៀលក្នុងមួយបាវ ។

ការណ៍ដែលប្រាក់ចុះថ្លៃ ទំនិញឡើងថ្លៃនេះ នាំឲ្យដម្លៃគ្រឹះស្ថានដែលកំពុងសង់ ឡើងថ្លៃដែរ, បើពុំនោះសោត អ្នកម៉ៅការ គេធ្វើតាមដម្លៃចាស់ តទៅទៀតមិនកើត គោងគេសុំទម្លាយកិច្ចសន្យាចោលចេញហើយឈប់ធ្វើតទៅ ។

ហេតុនេះ ទើបគណៈកម្មាធិការនាយកនៃសមាគម; ក្រោយដែលបានពិគ្រោះនឹងលោកវិស្វករ អ្នកត្រួតត្រាការតិកទិកនេះហើយ, ក៏បានព្រមព្រៀងជាមួយនឹងអ្នកម៉ៅការ ដំឡើងថ្លៃ៥០% ចាប់តាំងពីថ្ងៃទី៣០ ខែកញ្ញា គ.ស.១៩៥៣ តទៅ, គឺថាការណាដែលបានធ្វើរួចហើយ មុនថ្ងៃដែលចុះហត្ថលេខាលើកិច្ចសន្យាលើកក្រោយនេះ ត្រូវគិតតាមថ្លៃចាស់, ការណាដែលធ្វើក្រោយថ្ងៃ ខែកិច្ចសន្យានេះ ត្រូវគិតតាមថ្លៃថ្មី ។

ដោយហេតុនេះ ដំឡៃគេហដ្ឋាន ដែលគិតមុនជាង៥លាន ប្រែត្រឡប់ឡើងទៅជាជាង៦លានទៅវិញ ។

ការដែលនៅសល់មិនទាន់ធ្វើ ដម្លៃជាង៥លានរៀលទៀត, យើងនៅមានសល់ប្រាក់ក្នុងហិបជាង ១លាន៥សែនរៀល ឃើញថានៅខ្វះប្រាក់ ៣ លាន ៨សែនរៀលទៀត ។

ព្រះរាជរដ្ឋាភិបាលបានជួយក្នុងឆ្នាំ ១៩៥៣មួយលានរៀលប្រាក់នេះបានបើកយកមកហើយ, នៅខ្វះ ២លាន៨សែនរៀលទៀត ។

គណៈកម្មាធិការនាយក បានតាក់តែងធ្វើឃោសនាលើកទី២នេះទៀត, ដើម្បីយកប្រាក់មកបង្ហើយការកសាង ។

បើបានប្រាក់គ្រប់គ្រាន់ ដើម្បីបង្ហើយការកសាងក្នុងឆ្នាំ១៩៥៤នេះហើយ នឹងលេចឡើងនូវបញ្ហាថ្មីទៀត ដែលត្រូវដោះស្រាយដើម្បីធ្វើឲ្យសមាគមមានជីវិតរស់នៅតទៅ ។

បញ្ហានេះក៏គង់ស្រាយណាស់ដែរ ព្រោះហេតុការកសាងជាការប្រមូលមកគរ ។ គំនរនោះចេះតែធំៗឡើងរហូតដល់ពេញទំហំកំណត់ប៉ុណ្ណោះទៅ, ឯការលៀងជីវិតនៃសមាគម ជាការជួយនឹងការកសាងគឺជាគំនរដែលរកបានចេះតែតិចទៅៗ លុះត្រាតែអស់រលត់ជីវិតតែម្ដង បើប្រសិនជារកចំណូលថ្មីមិនបានទៀត ។

សេចក្ដីនេះក៏ប្រាកដណាស់ហើយ ងាយនឹងយល់ចិត្តផង ព្រោះមន្ទីរពេទ្យដែលកើតក្នុងអតីតកាលដោយសទ្ធានៃព្រះបរមក្សត្រនោះ មានជីវិតរស់នៅតែដោយកម្លាំងព្រះរាជទ្រព្យ នៃព្រះមហាក្សត្រអង្គ

នោះលុះផុតសេចក្ដីឧបត្ថម្ភព្រះមហាក្សត្រនោះទៅ មន្ទីរពេទ្យនោះក៏រលត់ជីវិតទៅដែរ ។

សមាគមគិលានសង្គ្រោះ ចំពោះព្រះសង្ឃពុទ្ធសាសនិកនេះ ជាសភាវៈមួយឥតរូប តែមានសិទ្ធិនិងករណីយកិច្ច បីដូចជាពលរដ្ឋទាំងឡាយក្នុងសង្គមដែរ ។

សមាគមនេះហើយដែលជាអ្នកបង្កើតមន្ទីរពេទ្យឲ្យនាមថា "គិលានសង្គ្រោះ" បីដូចជាសម័យបុរាណគេឲ្យឈ្មោះថា "គិលានសាលា" ឬ "អារោគ្យសាលា" ដែរ ។

សមាគមដែលបានបង្កើតមន្ទីរពេទ្យ ត្រូវមានករណីយកិច្ចចិញ្ចឹមថែរក្សាឲ្យមានជីវិតរស់នៅ ហើយបណ្ដុះបណ្ដាលឲ្យកើតគាលវាលគុម្ព មានគោលទ្រព្យបរិបូណ៌ ដើម្បីចិញ្ចឹមជីវិតឲ្យបានស្រួលតទៅ, បីដូចជាមាតាបិតាទាំងឡាយបំពេញ ចំពោះបុត្ររបស់ខ្លួននោះដែរ, តែថាករណីយកិច្ចដែលសមាគមបំរុងនឹងបំពេញនៅពេលឆាប់ៗនេះ ធំធូលាយលើសពីករណីយកិច្ចរបស់មាតាបិតាទាំងពួង ច្រើនណាស់; ជំនាន់បូរាណកាលពុំថា មានតែព្រះមហាក្សត្រដ៏ប្រសើរទេ ដែលបំពេញកិច្ចយ៉ាងនេះកើត ។

ព្រះគុណអើយ ករណីយកិច្ចដែលសមាគមអះអាងនឹងបំពេញនេះ មើលទៅក្លូតដូចជាហួសប្រមាណនិងសមត្ថភាពរបស់ខ្លួន ដែលហ៊ានប្រៀបផ្ទឹមនឹងសម្បត្តិព្រះមហាក្សត្រ តែបើបានពិចារណាឲ្យវែងឆ្ងាយទៅគង់មានសង្ឃឹមដោយមុតមាំថា នឹងធ្វើទៅកើត, ព្រោះព្រះរាជទ្រព្យនៃព្រះមហាក្សត្រដែលមានសម្បូរឥតគណនានោះ, ជាទ្រព្យបុគ្គល១រូប ។

ចំណែកសមាគមវិញ គ្មានទ្រព្យដូចព្រះមហាក្សត្រទេ, តែមានសមាជិកច្រើនរូបប៉ុណ្ណោះ ហើយក្នុងមួយរូបៗមានទ្រព្យបន្តិចបន្តួច ម្នាក់ៗតែថាបើប្រសិនជាប្រមូលបន្តិចៗ ច្រើនគ្នាកប់ពាន់-កប់ម៉ឺន-កប់សែនឡើងទៅ បន្តិចបន្តួចនោះ ត្រឡប់ជាធំជាដុំកំភួនពុំខាន,

សេចក្ដីឧបមានេះ យ៉ាងណាមិញ ជាសមាគមនេះមានសមាជិកសុទ្ធសឹងអ្នកក្រមានតែសទ្ធា, តែបើមានសមាជិកច្រើនកប់ម៉ឺន-កប់សែន ប្រមូលទ្រព្យបន្តិចៗម្នាក់ គង់កើតជាសម្បត្តិបរិបូរណ៍ ធ្វើការបានគ្រប់គ្រាន់ពុំខាន ។

បំពួកមួយទៀត សមាគមដែលហ៊ានប្រៀបផ្ទឹមនឹងសម្បត្តិព្រះមហាក្សត្រនោះ ដោយយល់ឃើញថាព្រះមហាក្សត្រមានតែមួយព្រះអង្គ បើអំណើសពីព្រះមហាក្សត្រនោះទៅ មន្ទីរពេទ្យក៏ក្ស័យជីវិតទៅដែរ ដោយខ្វះការឧបត្ថម្ភ ។

(នៅមានត)

# បកិណ្ណកកថា

## ពាក្យស្លោក

១-ជើងវែង, ធ្មេញល្អិត ស្លឹកត្រចៀកក្រប៉ុតក្អែក ទន្សាយ មនុស្សបែបនេះ បុរាណថាកុំឲ្យសេពគប់ ។

២- មុខកោងខ្នងស្វា ថ្ងាផ្ងាជ្រៅ ។

៣- ភាបតៀតុញ សុញប្រាជ្ញា ។

៤- ផ្គាមខ្វាបផ្កាហ៊ុង ពោះធំកំពីងក្បាលផ្សរខោច ។

៥- ករវែង ជន្លល់ទឹក ពោះសំបកឆ្ទឡឹក ចំពៀម ផ្សរខោច ។

៦- មុខសំពោច ខូចមិនលែង ។

៧- សក់រួញអង្គាដ ភ្នែកជ្រកព្រៃ គូថអ្នកទោស ។

* * *

## ដួងតារា

ភពដែលស្ថិតនៅជិតព្រះធរណី គឺព្រះចន្ទ្រ ស្ថិតនៅចម្ងាយ ៣៨៤.០០០គ.ម. ពីព្រះធរណី ស្មើនឹងរយៈផ្លូវដែលអាកាសយានប្រតិកម្មហោះ១០០០គ.ម. មួយម៉ោង, គាប់ហោះ ចំនួន ១៦ ថ្ងៃ ។

ព្រះអាទិត្យស្ថិតនៅឃ្លាតពីព្រះធរណី ចម្ងាយ ១៤៩.៥០០.០០០គ.ម. ១៧ ឆ្នាំដែលអាកាសយានប្រតិកម្មហោះ ក្នុង ៣០០.០០០គ.ម.មួយសីកុង ។

ផ្កាយដែលស្ថិតនៅជិតព្រះធរណី ជាងគេគឺចម្ងាយ ៣.៩១៥.៤១០.០០០ លាន គ.ម: ៤.៥០០.០០០ សតវត្សចំពោះអាកាសយានប្រតិកម្ម ; ៤ឆ្នាំនៃរស្មី (គេថាផ្កាយនេះ ស្ថិតនៅចម្ងាយ ៤ ឆ្នាំរស្មី) ។

ផ្កាយដែលល្អជាងគេនាមថាស៊ុរីយុស ស្ថិតនៅ ៩ឆ្នាំរស្មី ។

រូបលក្ខណៈនៃភពមានពណ៌ផ្សេងៗ ។ ពណ៌នេះឯងដែលគេអាចដឹងនូវកំសួលក្តៅភព, អាយុ, ទម្ងន់, សម្ភាព, បទបញ្ញត្តិ, ចលនា ។

* * *

## ប្រវត្តិសាស្ត្រខ្មែរបែកជាប៉ុន្មានសម័យ ?

ប្រវត្តិសាស្ត្រខ្មែរបែកជា៥សម័យគឺ :

១- សម័យនគរភ្នំ (ហ្វូណន) ជាសម័យដំបូង តាំងរាជធានីនៅនគរបុរី ឬ បាភ្នំហៅថាវ្យាធរៈ :

២- សម័យនគរធំ តាំងរាជធានីនៅក្នុងខេត្តសៀមរាបសព្វថ្ងៃនេះ;

៣- សម័យលង្វែក, តាំងរាជធានីនៅស្រុកលង្វែក ,

៤- សម័យឧត្តុង្គ តាំងរាជធានីនៅស្រុកឧត្តុង្គ;

៥- សម័យភ្នំពេញ តាំងរាជធានីនៅស្រុកភ្នំពេញគឺទីក្រុង សព្វថ្ងៃ ។

* * *

## អ្វីដែលហៅថាមាឃបូជា ?

មាឃបូជាគឺបូជាខែមាឃ ជាពិធីបុណ្យមួយក្នុងព្រះពុទ្ធសាសនា រំឭកដល់ថ្ងៃនក្ខត្តឫក្សដែលព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងទ្រង់បានធ្វើចតុរង្គសន្និ-បាត ដោយព្រះរាជទានឱវាទបាតិមោក្ខដល់ព្រះភិក្ខុ

ដែលជាព្រះអរហន្ត ១២៥០ រូប ។

ចតុរង្គសន្និបាតប្រកបដោយអង្គបួនគឺៈ

១ – ព្រះចន្ទ្រចូលទៅក្នុងថ្ងៃឧបោសថប្រកបដោយផ្កាយនក្ខត្តឫក្សមាឃនក្សត្រ,

២ – ព្រះភិក្ខុ ១២៥០ រូបឥតបានមកណាត់គ្នាជាមុន,

៣ – ព្រះភិក្ខុជាឯហិភិក្ខុ,

៤ – ភិក្ខុជាព្រះអរហន្ត ។

មួយយ៉ាងវិញទៀត, នៅថ្ងៃពេញបូណ៌មីខែមាឃ ព្រះមានព្រះភាគបានប្ដេជ្ញានឹងមារថា បីខែទៀតទ្រង់នឹងដាក់ព្រះជន្មាយុចូលបរិនិព្វាន ។

* * *

## អ្វីដែលហៅថាវិសាខបូជា?

វិសាខបូជា គឺបូជាខែវិសាខជាពិធីបុណ្យមួយក្នុងព្រះពុទ្ធសាសនា, ជាអនុស្សាវរីយ៍ចំពោះថ្ងៃដែលព្រះសាស្ដាទ្រង់ប្រសូត, ត្រាស់ដឹងនឹងបរិនិព្វាន ។

* * *

## ក្បួនបុរាណទូន្មានបិៈ

កាលនឹងទៅគាល់ព្រះរាជា ១ ទៅរកឧបជ្ឈាយ៍ ១
ទៅរកតុលាការ ១ ទៅរកស្រីក្រមុំ ១
ទៅរកស្រីចាស់ដែលមានកូនក្រមុំយើងចង់បាន១
គួរចាំទុកថាកុំទៅដោយដៃទទេ ។

* * *

មនុស្សច្រើនពួក ដែលយើងត្រូវ ទៅរក
គួរកាន់យក គ្រឿងបណ្ណាការទៅផង
កុំបីទៅ ដៃទទេ នាំមួយផង
សូមអ្នកផង ចាំទុកចុះ កុំសង្ស័យ ។
មួយនោះគឺអង្គព្រះរាជា
ពីរគឺឧបជ្ឈាយ៍ ត្រូវសព្វថ្ងៃ
បីនោះគឺតុលាការកាត់ក្ដី
បួននោះគឺស្រីនៅក្រមុំ ។
ប្រាំនោះគឺស្រីចាស់ជរា
តែមានធីតារូបស័គសម
ដែលយើងមានចិត្តចាប់អារម្មណ៍
ចង់បានរៀបចំជាគូគាប់ ។
ត្រូវយើងកាន់យកវត្ថុអ្វី
ឲ្យជាប់នៅដៃទៅគំនាប់
ទើបបានសម្រេចកិច្ចផលភ័ព្វ
អ្នកស្ដាប់ចាំទុកកុំភ្លេចអើយ ។

---

## រឿងបញ្ចតន្ត្រៈ

(តពីទស្សនាវដ្ដីលេខ ១២- ៥២)

លុះបានស្ដាប់ពាក្យទន្សាយហើយ ការុកៈនិយាយថា " សំឡាញ់អើយ! បើទុកជាសីហៈពាលនោះវានៅក្នុងបន្ទាយមាំក៏ដោយ ចូរឯងប្រាប់ទីកន្លែងវាឲ្យចាប់មក អញនឹងទៅសម្លាប់វាឲ្យដល់ក្ដីមរណ៍ឥឡូវនេះ ព្រោះថាៈ –

២៣៣ – នរជនណា មិនបំផ្លាញសត្រូវ ឬជម្ងឺខ្លួន ក្នុងពេលវាទើបនឹងកើតឡើងទេ នរជននោះ

សូម្បីខ្លាំងពូកែយ៉ាងណាក៏ដោយ កាលវាចំរើនធំឡើង ត្រូវវាសម្លាប់ខ្លួនឯងវិញមិនខានឡើយ ។

២៣៤ – ឯសត្រូវ កាលកំពុងកកើតឡើង អ្នកប្រាថ្នាសេចក្តីចំរើនមិនត្រូវព្រងើយកន្តើយ (ត្រូវបញ្ជាប់រំលត់ទៅ) រោគក្តី សត្រូវក្តី កាលបើកើតហើយ បេះតែចំរើនឡើង ៗ បានជាអ្នកប្រាជ្ញលោកពោលថា រោគក្តី សត្រូវក្តី មានទំនងដូច ៗ គ្នា ។

២៣៥ – សត្រូវ ដែលមានកំឡាំងតិច បុគ្គលល្ងង់ខ្លៅតែងតែព្រងើយកន្តើយ មើលងាយ ព្រោះទោសមកពីសេចក្តីប្រមាទ ។ សេចក្តីពិត, សត្រូវទើបកើតមុនដំបូង គេអាចរំលត់បានជាធម្មតា, តទៅមុខ កាលបើចំរើនធំឡើងហើយបុគ្គលមិនអាចរំលត់បានទេ ដូចជាព្យាធិ (ដែលកើតខ្លាំងហើយ គេរក្សាមិនបានដូច្នោះដែរ) ។

២៣៦– នរជនណា មើលឃើញកំឡាំងខ្លួន ហើយបញ្ចេញព្យាយាមឲ្យពេញទំហឹង នរជននោះ សូម្បីតែម្នាក់ឯង ក៏អាចសម្លាប់សត្រូវបានដែរដូចភាគ៌វៈ(១) សម្លាប់ក្សត្រទាំងឡាយ ” ។

ទន្សាយ និយាយទៅទៀតថា. “ ដំណើរយ៉ាងនេះ ក៏តែងកើតមានដែរ តែមុនដែលលោកអញ្ជើញទៅ ត្រូវឲ្យដឹងកំឡាំងសត្រូវមុនសិន ព្រោះថា: –

២៣៧– នរជនណាមិនទាន់ដឹងកំឡាំងរបស់ខ្លួននឹងរបស់សត្រូវមុនទេ ហើយចូលទៅចំពោះមុខសត្រូវ នរជននោះនឹងត្រូវវិនាសខ្ទេចដូចកណ្តូបបោលចូលភ្លើង ។

២៣៨- នរជនណា សូម្បីមានកំឡាំងខ្លាំង ដើម្បីសម្លាប់សត្រូវដែលមានកំឡាំងប៉ុនខ្លួនដែរ នរជននោះ កាលត្រឡប់មកវិញ នឹងទៅជាបុគ្គលអស់ក្លៀវក្លាដូចដំរីបាក់ភ្លុក” ។

សីហៈភាសុរកៈ ស្រែកខ្លាំង ៗ ថា: ដូចម្តេចក៏ដោយ ! ប្រាប់អញមកវានៅទីកន្លែងឯណា ? បើទុកជាវាមកនៅក្នុងរូងភ្នំ អញក៏មិនខ្លាចដែរ ។

ទន្សាយឆ្លើយតបថា: “បើដូច្នោះ សូមលោកម្ចាស់អញ្ជើញមកតាមខ្ញុំ” ។ ទន្សាយនិយាយហើយ នាំសីហៈនោះដើរទៅ ទៅដល់អណ្តូង បែរនិយាយទៅកាន់សីហៈថា: “លោកម្ចាស់! នរណាមួយ ដែលអាចហ៊ានតស៊ូលោកម្ចាស់បាន ? មើលចុះ! អាចោរខិលនេះ កាលវាឃើញលោកម្ចាស់អញ្ជើញមកពីចម្ងាយវាលិចចូលទៅបន្ទាយវា សូមអញ្ជើញចូលមក! ខ្ញុំបាទចង្អុលប្រាប់” ។ កាលសីហៈភាសុរកៈបានស្តាប់ពាក្យទន្សាយនិយាយហើយ សួរដដែល ៗ ថា: “នែសំឡាញ់! ប្រាប់អញឲ្យរហ័សមក តើបន្ទាយវានៅឯណា?” ។ ទន្សាយចង្អុលប្រាប់ថា: “ អណ្តូងនេះហើយជាបន្ទាយវា” ។

---

១ បរសុរាម ។ បរសុរាមនេះ ជាអវតារនៃព្រះនារាយណ៍ បានសម្លាប់ពួកក្សត្រស្ទើរតែអស់រលីង តាំងពីបុរាណកាល ។

កាលនោះសីហៈល្ងង់ លុះបានឃើញស្រមោលខ្លួននៅកណ្តាលអណ្តូង ក៏បញ្ចេញសំរែកគ្រលួរខ្ទរខ្ទា រពងគឹកកង ៗ សីហៈនាងនេះក៏រពងចេញសំឡេងពីក្នុងអណ្តូងតបតមកវិញ ដ៏ខ្លាំងជាងសំរែកខ្លួនទៅទៀត ៗ កាលសីហៈបានឮសំឡេងរពងតមកវិញនោះគិតថា: "អៃយ៉ា! អាចោរសីហៈនេះធំខ្លាំងណាស់តើ!" គិតហើយក្តៅចិត្តខ្លាំងណាស់ លោតចុះក្នុងទៅក្នុងអណ្តូងជ្រៅនោះភ្លាម ក៏ដល់ក្តីមរណ៍ទៅហោង ៗ ទន្សាយឃើញសីហៈស្លាប់ហើយ រីករាយសប្បាយចិត្តណាស់ យកដំណឹងនេះទៅប្រាប់សត្វម្រឹគទាំងឡាយឲ្យបានសប្បាយរីករាយទាំងអស់គ្នា ៗ សត្វទាំងឡាយបបួលគ្នាមកជូនឲ្យពរសព្ទសាធុការសរសើរប្រាជ្ញា ទន្សាយហើយនៅជាសុខសប្បាយគ្រប់គ្នាក្នុងពនាល័យនោះរៀងតទៅ ៗ ព្រោះហេតុនោះ បានជាខ្ញុំ (ចចកទមនកៈ) ពោលថា: "នរណាមានប្រាជ្ញា" ដូច្នេះជាដើម ៗ

បើដូច្នោះឲ្យតែឯងព្រមព្រៀង ក៏នៅឯណារូបខ្ញុំនឹងទៅកាន់កន្លែងការនេះ ហើយនឹងបំបែកបំបាក់ក៏ទាំងពីរឲ្យបែកសាមគ្គីគ្នា ដោយកំឡាំងប្រាជ្ញាកលឧបាយរបស់រូបខ្ញុំ ៗ ចចកករដកៈ ឆ្លើយតបថា: « អើសំឡាញ់ ! ឯងទៅឥឡូវនេះចុះ ចូរឲ្យឯងប្រកបដោយសុភមង្គលតាមផ្លូវ ហើយចូរឲ្យការងារឯងបានសម្រេចតាមបំណងកុំខាន" ៗ

លំដាប់នោះ, ចចកទមនកៈ ឃើញបិង្គលកៈនៅឃ្លាតឆ្ងាយពីសញ្ជីវកៈ ក៏ចៀតឱកាសលបចូលទៅជិតរកបិង្គលកៈ ទៅដល់ហើយ ក្រាបប្រណិប័តន៍ដោយបេះស្តាង្គបាត ទើបអង្គុយក្នុងទីសមគួរមួយនៅចំពោះមុខសីហៈ ៗ បិង្គលកៈសួរទៅកាន់ចចកទមនកៈថា: "ហៃសំឡាញ់! យូរយារណាស់ហើយ យើងមិនដែលឃើញមុខបាសោះ ឯងគាល់យ៉ាទៅឯណា ព្រោះហេតុអ្វីបានជាឯងមករកយើង ៗ ចចកទមនកៈឆ្លើយតបថា: "បពិត្រលោកម្ចាស់! លោកម្ចាស់មិនមានត្រូវការនឹងយើងខ្ញុំសោះ ព្រោះហេតុនោះបានជាយើងខ្ញុំមិនបានមក បើទុកជាដូច្នោះក៏ដោយ ពេលនេះនឹងខានមកជួបលោកម្ចាស់ពុំបាន ព្រោះខ្ញុំបាទឃើញមានហេតុការណ៍ អន្តរាយដល់កាយលោកម្ចាស់ ខ្ញុំបាទក៏មានចិត្តព្រួយបារម្ភខ្លាំង ដោយការព្រួយបារម្ភនេះ ទើបខ្ញុំបាទកាត់ចិត្តកាត់ថ្លើមចូលមកដើម្បីជំរាបលោកម្ចាស់ផ្ទាល់ខ្លួន, ព្រោះថា: —

២៣៩— កិច្ចការណាមួយ ល្អក្តី មិនល្អក្តី គួរជាទីស្អប់ខ្ពើមក្តី ជាទីស្រឡាញ់ពេញចិត្តក្តី បុគ្គលណាប្រាថ្នាសេចក្តីចំរើនដល់អ្នកណា បើទុកជាអ្នកនោះមិនសាកសួរក៏ត្រូវតែប្រាប់កិច្ចការនោះ ដល់អ្នកនោះ " ៗ

កាលបិង្គលកៈ បានស្តាប់ពាក្យអក់ប្រាយចចកហើយ សួរតបទៅវិញថា: " ចុះឯងចង់ជួបម្តេច ? និយាយមកមើល ! " ៗ ចចកទមនកៈ

និយាយប្រាប់ថា: "សញ្ជីវកៈនេះមានចិត្តក្បត់លោកម្ចាស់ហើយ រឿងនេះខ្ញុំបាទបានដឹងអស់ព្រោះខ្ញុំបាទបានចងមេត្រីភាពជាស្និទ្ធស្នាលទាល់តែវាទុកចិត្ត វាបាននិយាយប្រាប់ខ្ញុំបាទអស់អាថ៌កំបាំងក្នុងចិត្តថា: "នែទមនកៈ! រូបខ្ញុំនេះ បានឃើញចំណុចខ្លាំង នឹងចំណុចខ្សោយនៃបិង្គលកៈអស់ហើយ ខ្ញុំនឹងសម្លាប់វាពេលបន្តិចទៀតហើយនឹងឡើងសោយរាជ្យគ្រប់គ្រងសត្វនិករទាំងឡាយ ហើយរូបឯងនេះ យើងនឹងតាំងឲ្យធ្វើជានាយករដ្ឋមន្ត្រីផ្តួចការផែនទឹកផែនដីតទៅ» ៕ កាលបិង្គលកៈបានឮពាក្យមិនពិរោះដ៏អាក្រក់ក្រៃលែង ប្រាកដដូចជាគេប្រហារដោយអស្សនីបាតដូច្នេះហើយ រន្ធត់តក់ស្លុតក្រៃលែង តែនៅស្ងៀមទ្រឹងមិនមាត់កថាដូចម្តេចសោះ ៕ ចចកទមនកៈឃើញបិង្គលកៈ នៅស្ងៀមទ្រឹងនឹកក្នុងចិត្តថា "បិង្គលកៈនេះមានចិត្តស្រឡាញ់សញ្ជីវកៈនេះណាស់ ព្រោះតែព្រះរាជាទាំងឡាយទុកចិត្ត មន្ត្រីព្រះអង្គយ៉ាងនេះហើយ បានជាទ្រង់តែងដល់នូវអន្តរាយបាតភពដ-បល័ក្ខពិតប្រាកដ, ព្រោះថា: –

៤៤០- ព្រះរាជាអង្គណាប្រគល់កិច្ចការរាជការឲ្យមន្ត្រីតែម្នាក់ធ្វើការជាចំពាត សេចក្តីស្រវឹងនឹងគ្រប-សង្កត់មន្ត្រីនោះដោយអំណាចមោហៈលុះមន្ត្រីនោះកើតមានសេចក្តីស្រវឹងហើយ នឹងកើតធុញទ្រាន់ការនៅជាខ្ញុំបំរើ កាលបើធុញទ្រាន់កើតមានហើយ សូតន្ត្រៈ (សេចក្តីប្រាថ្នាផ្តាច់ការតែម្នាក់ឯង) ក៏កើតឡើងទៀត សូតន្ត្រៈកើតឡើងហើយ មន្ត្រីនោះនឹងធ្វើគតព្រះរាជានោះចោលបង់មិនខាន ៕

បើដូច្នេះតើត្រូវធ្វើដូចម្តេចគួរហ្ន៎?" ៕ កាលនោះសីហៈបិង្គលកៈ បានស្តាប់ពាក្យចចកទមនកៈហើយ នៅស្ងៀមទ្រឹងមួយស្របក់ ទើបនិយាយថា: "នែទមនកៈ! សញ្ជីវកៈនេះ ជាអាមាត្យជាទីស្រឡាញ់ស្មើជីវិត ម្តេចវានឹងមានគំនិតអាក្រក់ប្រឆាំងក្បត់យើង?» ៕ ចចកទមនកៈ ឆ្លើយថា: "អាមាត្យក្តីមិនមែនជាអាមាត្យក្តី មិនជាការសំខាន់អ្វីប៉ុន្មានទេ, ព្រោះថា: –

៤៤១- ចុះនរណា បានកើតជាមនុស្សហើយមិនចង់បានសោយរាជ្យ? មិនមានទេ! ក្នុងចំណោមពួកមនុស្សដែលមិនមានអំណាច តែងចង់បានជាព្រះនរេន្ទ្រាធិបតី ដោយពិត» ៕

បិង្គលកៈពោលថា: "សំឡាញ់អើយ! ធ្វើដូចម្តេចហ្ន៎: បើចិត្តយើងមិនផ្លាស់ប្តូរ លះបង់វាមិនកើតសោះ, ព្រោះថា: –

៤៤២ – កាយយើងនេះមានទោសគឺរោគ ប-ទូស្តច្រើនណាស់ តើនរណា ដែលលះបង់មិនស្រឡាញ់កាយខ្លួនឯង? នរណាដែលស្រឡាញ់យើង បើទុកជាមានធ្វើការខុសចំពោះយើងខ្លះ អ្នកនោះក៏នៅតែស្រឡាញ់យើងដែរ" ៕

ចចកទមនកៈ ឆ្លើយតបវិញថា: " ឯទោស ក៏

តែងមានយ៉ាងនេះហើយ តែលោកពោលថាៈ –

២៤៣ – ព្រះនរបតីទាំងឡាយ តែងទតព្រះនេត្រចំពោះនរជនណាច្រើនជាងគេ នរជននោះ ពោះជាឥតត្រកូលក្តី មានត្រកូលក្តី នឹងបានជាភាជន៍ សំរាប់ត្រងរងនូវព្រះស្រីគឺទ្រព្យសម្បត្តិទាំងឡាយ ។

មួយទៀត, លោកម្ចាស់មិនគួរថែរក្សាសញ្ជីវកៈនេះទុកក្នុងតំណែងខ្ពស់ទេ ព្រោះវាមិនមានគុណវិសេសអ្វីទេ ប៉ុន្តែលោកម្ចាស់គិតថាសញ្ជីវកៈ មានរូបធំមាំ អាត្មាអញទុកគ្រាន់ជាជំនួយជួយបំផ្លេចបំផ្លាញសត្រូវ លោកម្ចាស់ត្រិះរិះដូច្នេះមិនត្រូវទេ ព្រោះសញ្ជីវកៈនេះជាសត្វស៊ីស្មៅជាអាហារ ឯសត្រូវលោកម្ចាស់សុទ្ធតែសត្វស៊ីសាច់ ហេតុនេះ ក្នុងការសង្គ្រាមសត្រូវមិនចាំបាច់ពឹងគោស៊ីស្មៅឲ្យជួយទេ ត្រូវតែសម្លាប់វាចោលបង់ភ្លាមទៅ,, ។

បិង្គលកៈ ឆ្លើយទាស់ថាៈ –

២៤៤ – នរជនណា មានគេនិយាយសរសើរក្នុងទីសន្និបាតថាជាបុគ្គលមានគុណ បុគ្គលមិនគួរគប្បីចោទប្រកាន់ទោសនៃនរជននោះ ព្រោះតែភ័យខ្លាចជាប់ពាក្យប្ដេជ្ញាទេ ។

មួយទៀត, យើងបានពោលរួចហើយថា នឹងថែរក្សាសញ្ជីវកៈ ឲ្យបានសេចក្តីសុខ បើដូច្នោះហើយ យើងនឹងទៅសម្លាប់វាដូចម្ដេចកើត? បើពោះជាយ៉ាងណា វាជាមិត្តនឹងយើងផង មិនត្រូវទៅបៀតបៀនគ្នាទេ; ព្រោះថាៈ-

២៤៥ – ទៃត្យៈ[1]នេះ គឺយើងបានប្រគល់ស្រ[2]ឲ្យហើយ យើងមិនគួរនឹងបំបាត់ជីវិតវាដោយខ្លួនឯងទេ ដូចជាដើមឈើមានពិសពុលដែលគេបណ្ដុះបណ្ដាលឲ្យចំរើន គេមិនគួរនឹងទៅកាត់ចោលខ្លួនឯងទេ ។

២៤៦ – មុនបង្អស់, បុគ្គលមិនគួរបង្ហាញមេត្រីចំពោះនរជនណាដែលគេមិនមានមេត្រីនឹងខ្លួនសោះ ថាបើបានជាពប់គេហើយ ត្រូវតែរក្សាប្រោះប្រាណពល់ៗថៃទៅ, ការបោះបង់ចោលអ្វីមួយដែលគេរើសយកមកហើយ មិនល្អមើលទេ ធ្វើយ៉ាងនេះមុខគួរអាម៉ាស់មុខណាស់; ការភ័យខ្លាចពីការធ្លាក់នៃបុគ្គលដែលឋិតនៅលើផែនដី មិនដែលមានទេ ។

២៤៧ – នរជនណា ធ្វើសេចក្តីល្អចំពោះបុត្រការីទាំងឡាយរបស់ខ្លួន គួរនឹងសរសើរគុណនរជននោះថា ដូចម្ដេចទៅហ្ន៎? នរជនណា ធ្វើសេចក្តីល្អចំពោះជនដែលប្រព្រឹត្តអាក្រក់ ការប្រព្រឹត្តិធ្វើនៃនរជននោះ អ្នកប្រាជ្ញលោកពោលថាជាសេចក្តីល្អរបស់សាធុជន ។

ដូច្នេះ បើទុកជាសញ្ជីវកៈនេះវាប្រុងធ្វើគត់ក្បត់ចំពោះយើង យើងក៏មិនគួរនឹងប្រកាន់ទោសធ្វើតបវិញ

១. ទៃត្យៈជាកូននៃទិតិ ជាភរិយានៃព្រះកស្សបៈ ។ ទៃត្យៈជាបច្ចាមិត្តនៃទេវតា ។ ត្រង់នេះបានសេចក្ដីថា "ទុកជាកូនខ្លួន" ។

២. ភក្ស, ស៊ី, អំណាច។ល។

ទេ ។ ចចកទមនកៈឆ្លើយប្រឆាំងថា៖ លោកម្ចាស់! ការប្រោសប្រណីទោសដល់ជនក្បត់ ចំពោះលោកម្ចាស់យ៉ាងនេះ មិនមែនជាធម៌នៃលោកដែលជាម្ចាស់ជីវិតទេ, ព្រោះថា:-

២៤៨ – ព្រះរាជាអង្គណាមិនសម្លាប់អាមាត្យណាមួយដែលមានទ្រព្យស្មើព្រះអង្គ មានសមត្ថភាពស្មើព្រះអង្គ មានប្រាជ្ញាឆ្លៀវឆ្លាត មានគំនិតដាច់ខាត ហើយបានដណ្ដើមយករាជ្យពាក់កណ្ដាល ទៅហើយផង ព្រះរាជាអង្គនោះនឹងត្រូវគេធ្វើគត់ជាពលីថ្វាយវិញមិនខាន ។

ដោយមេត្រីភាព ដែលលោកម្ចាស់ចុះនឹងព្រោះប្រណីដល់សញ្ជីវកៈនេះ លោកម្ចាស់បណ្ដែតបណ្ដោយការរាជការបោលបង់អស់ អាមាត្យមុខមន្ត្រីទាំងឡាយក៏លែងមានស្វាមីភក្តិគោរពលោកម្ចាស់ នោះ ព្រោះតែលោកម្ចាស់ធ្វេសប្រហែសកិច្ចការរាជការនេះឯង ។ ឯសញ្ជីវកៈនេះជាសត្វស៊ីស្មៅជាអាហារ តែកិច្ចការនេះជាប្រក្រតីទេ ។ បើលោកម្ចាស់នៅតែរឹងទទឹងធ្វើដូច្នេះតទៅទៀត មុខជានឹងមានភ័យក្ស័យព្រះអង្គមិនខាន ។ មួយវិញទៀត បើលោកម្ចាស់មិនឈ្វេងយល់ថាជាទោសទេ បរិពារលោកម្ចាស់ទាំងឡាយនឹងបានសាច់មកពីណាជាអាហារ? តទៅបរិពារទាំងឡាយនឹងលះបង់ចោល លោកម្ចាស់អស់ លោកម្ចាស់នឹងមិនមានបរិពារ ព្រោះគេរត់ចោលទៅនៅព្រៃផ្សេងអស់ហើយ លោកម្ចាស់នឹងវិនាសមិនខានដោយពិត ។ បើលោកម្ចាស់នៅតែគប់សញ្ជីវកៈទៀត មុខជាលោកម្ចាស់មិនមានសក្តិដើរបបាញ់ចាប់សត្វជាអាហារទេ, ព្រោះថា:-

២៤៩ – បុរស ដែលសេពគប់ដោយអាមាត្យបែបណា ឬក៏គប់នូវអាមាត្យណា នឹងទៅដូចជាអាមាត្យនោះប្រាកដ ដំណើរនេះ ឥតមានសង្ស័យឡើយ ។

២៥០ – ទឹកដែលបិតនៅលើដែកក្ដៅ មិនប្រាកដឈ្មោះទេ ទឹកនេះឯងកាលបើបិតនៅលើស្លឹកឈូកនឹងភ្លឺផ្លេក មានអាការៈដូចជាគុជៈ បើបិតនៅក្នុងពោះខ្យងនៃសាគរនៅក្រោមផ្កាយស្វាតិ[១] នឹងកើតទៅជាកែវមុក្តាពិត ៗ តាមធម្មតា បុគ្គលដែលនឹងបានទៅជាបុគ្គលឧត្តម, មធ្យម ឬថោកទាប ស្រេចហើយតែសង្គមដែលខ្លួនសេពគប់ទេ ។

២៥១ – សាធុជនទាំងឡាយធ្លាក់ខ្លួនទៅជា ;- គ្គលមិនមានចិត្តប្រសើរ ព្រោះទោសនៃការសេពគប់អសប្បុរសទាំងឡាយ ចូរមើល? ពីស្មៈ[២] ត្រូវចប់ទៅជាចោរលួចគោ ព្រោះតែការសេពគប់ទុយោធន៍[៣] ។

ព្រោះហេតុនោះ សប្បុរសទាំងឡាយលោកវៀរចាកការសេពគប់ចំពោះបុគ្គលថោកទាប, ព្រោះថា:,

១- ផ្កាយនក្ខត្តឫក្ស ទី ១៣ និង ១៥ ។ ២- ពីស្មៈជាព្រះជេដ្ឋានៃក្សត្រកោរវៈ ។ ៣- ទុយោធន៍នេះត្រូវជាបិតុលានៃក្សត្រប៉ាណ្ឌុនិងក្សត្រត្រិស្ដរាស្ត្រ ។

២៥២– បុគ្គលមិនគួរគប្បីឲ្យទីសំណាក់អាស្រ័យ ដល់ជនណាមួយដែលខ្លួនមិនស្គាល់ចរិយា ថៃ ឈ្មោះ មន្ទីរសំបិណាំត្រូវគេសម្លាប់ ព្រោះទោសមកពីសង្គ្រោះ ឈ្មោះអគ្គិមុខ " ។

សីហៈបិង្គលកៈសួរថា៖ " ចុះរឿងនោះតើដូចម្ដេច ៗ ចចកទមនកៈរៀបរាប់ប្រាប់ថា៖–

(នៅមានត)

# ប្រវត្តិនៃក្មេងកំព្រាម្នាក់



នៅផ្លូវត្រួសមួយ. មានដើមជាប់ពីទីដែដុំផ្ការ ដំណាក់បន្ទើរ, ដែលក្រុមគន្ធាទីនក្រុងបង្កើតឡើង សម្រាប់ដើរពិនិត្យនៃភ្នាក់ងារក្រុងការក្សា; ផ្លូវនោះមានទុកជាផ្លូវបណ្ដោយទៅ តាមដើមក្នុងវល្លិ៍ទល់ទីនគ្រប់ពាំង កក់ ៗ នៅតាមផ្លូវនេះ, កាលដើមសុខតែជាលំនៅ នៃប្រជាជាតិចិនថៃហណ៌ា ដែលមានដំណាំម្រេចជារបរនៅទីនោះ; កាលដែលវត្តកម្មជានោជាអាណា-និគមរបស់ជនបរទេសនៅឡើយ ជាតិចិនអ្នកចំការនៅទីនោះ មានភាគបច្ចុំរិយោដូចជាអ្នកក្នុងប្រទេសជាតិរបស់ខ្លួន ។

ក្នុងបណ្ដាជនអ្នកចំការទាំងឡាយ, គេឃើញមានជនចំណាស់ម្នាក់ ដែលមានសញ្ញាតិជាអ្នកក្នុងវត្តគាត់ មានអាជីវកម្មរស់នៅដោយសារអ្នកចំការទាំងនោះដែរ, លំនៅរបស់គាត់ក៏នៅមិនឆ្ងាយពីជនបរទេសទាំងនោះប៉ុន្មាន ។ គាត់ជាទេមរជាតិមួយរូបដែលឧស្សាហ៍បំផុតខាងការបង្កើតផលដំណាំ តាំងពីកិរិយារបស់គាត់មានជីវិតរស់នៅនៅឡើយ; ទុកណាជាគាត់មានសេចក្ដីទុក្ខព្រួយគ្រប់សព្វគ្រប់ដូចម្ដេចក៏ដោយ ក៏គាត់នៅមានទសចរិសេស គឺកូនប្រុសមួយរូបអាយុប្រមាណជាប្រាំឆ្នាំ គ្រាន់ញញឹមទទួលផ្លូវគាត់ក្នុងពេលដែលមកពីធ្វើការឈ្នួលវិញ គាត់តែងហៅកូនគេថាសំណាង; សុភាពរបស់គាត់ក៏ចេះតែមានជាដរាបរៀងមក ។

២ ឆ្នាំក្រោយមក គឺក្នុង គ.ស. ១៩៣៧, គាត់ទទួលទណ្ឌកម្មយ៉ាងធ្ងន់ដោយការបៀតបៀនរបស់កម្មករជាតិចិនទាំងឡាយ; ការបៀតបៀននេះ ខ្ញុំជាអ្នកនិពន្ធក៏មិនអាចនឹងរកដើមចុងបានឡើយ, គ្រាន់តែបានដឹងថា កម្មករចំការម្រេចទាំងឡាយព្រួតគ្នាប្រហារគាត់ ហើយអូសយកទៅចោលនៅក្បែរដើមក្លុ ដូចជាសត្វតិរច្ឆាន ។ តើជនអ្នករងគ្រោះនេះទទួល

មរណៈហើយឬនៅ? បើតាមអ្នកប្រហារថា ជននេះត្រូវស្លាប់ទៅហើយ តែបើតាមការពិត. គាត់នៅមានជីវិតរស់នៅឡើយទេ; ក្នុងបច្ចិមយាមសន្សើមធ្លាក់ជោគជាំសរុកជាតិ អ្នករងគ្រោះចាំខ្លួនក្នុងពេលនោះ, តែដោយការប្រហារដំខ្លាំងបែបនេះ គាត់មិនអាចនឹងដកខ្លួនចេញពីព្រៃស្មសាននោះបានឡើយ ។

ពេលនោះជារដូវរុក្ខផលទៅព្រៃភ្នំ ប្រជាជនប្រុសស្រីបបួលគ្នាចេញពីគេហស្ថានតាំងពីបច្ចិមយាមដើម្បីរកបេះរុក្ខផលទាំងឡាយ មានមាក់ប្រាង, សេមាន់ជាដើម ជនទាំងឡាយតែងសប្បាយរីករាយជានិច្ច ក្នុងពេលធ្វើដំណើរកាត់ដងព្រៃ លំនៅអ្នករងគ្រោះនឹងអ្នកដំណើរប្រហែលជាប្រទះគ្នាក្នុងពេលនោះ;ក្មេងតូចទំនិងស្រីតែងតែរត់មុន បន្ទាប់មកជនអ្នកដើរមុនក៏បន្ថយដំណើរថយក្រោយវិញ ជនអ្នកដើរព្រៃទាំងឡាយក៏ស្ងាត់សំឡេង, ក្នុងពេលដ៏ស្ងាត់នេះគេឃើញមនុស្សទាំងអស់មានអាការហាក់ដូចជាប្រឹង ។ សំឡេងថ្ងូរយ៉ាងធ្ងន់ដែលឮហាក់ដូចជាស្រែក, លេចចេញពីព្រៃស្មសាន, ក្នុងបណ្ដាជនអ្នកឈរត្រចៀកស្ដាប់ទាំងនោះ គ្មានអ្នកណាមួយស្មានបានថា ជាសំឡេងមនុស្សទេ ព្រោះទីនោះជាព្រៃដែលសម្រាប់ចោលទូវសាកសព; សូមលោកអ្នកអានទាំងឡាយជ្រាបបានថា ក្នុងក្រុមជនទាំងនោះមិនសុទ្ធតែមនុស្សខ្លាចទាំងអស់នោះទេ តែងមានអ្នកក្លាហាននៅជាប់ជាមួយផង ។ បន្ទាប់មក មានសំឡេងនិយាយឡើងថា យើងទាំងអស់គ្នាមិនត្រូវធ្វើជាអ្នករាថយក្រោយទេ គួរតែយើងពិនិត្យឲ្យច្បាស់តើហេតុនោះជាអ្វី? សំឡេងច្រើនក៏ឆ្លើយឡើងថាទៅក៏ទៅ! សំឡេងថ្ងូរគាត់តែច្បាស់ដល់ត្រចៀកអ្នកស្ដាប់ឡើង, ឱ! លោកអើយមេត្តាជួយយកជីវិតខ្ញុំផង! ។

ប្រហែលជាមួយវិនាទីក្រោយមកជនទាំងឡាយក៏បានដឹងច្បាស់ថា នេះជាអំពើអយុត្តិធម៌របស់កម្មករជនបរទេស; គួរឲ្យអាសូរដល់អ្នករងគ្រោះនោះណាស់ ពេលដែលគាត់បានប្រទះនឹងជនអ្នករួមសញ្ជាតិដូច្នេះ គាត់មិនអាចពណ៌នាឲ្យវែងឆ្ងាយបានទេ ដោយមច្ចុរាជបោះតែចូលមកគំរាម ទីបំផុតគាត់ចំលើកដៃចង្អុលទៅលំនៅរបស់គាត់ ថាកូនប្រុសខ្ញុំនៅទីនោះ....ខ្យល់អស្សាសៈបស្សាសៈក៏រលត់ក្នុងខណៈនោះភ្លាម ៗ ជនទាំងឡាយនាំគ្នា សែងសពកំសត់នេះទៅកាន់ទីដែលគាត់ចង្អុល ចុះទីនោះជាអ្វី? ដើមឡើយទីនោះជាលំនៅរបស់សពនេះ ឥឡូវដូចម្ដេចក៏ក្លាយទៅជាផេះនិងធ្យូង? កាលដែលកម្មករទុជ៌ន បានប្រហារសពនេះហើយ ក៏បបួលគ្នាមកដុតផ្ទះនេះចោលទៀត; ចុះសំណាងជាកូនគាត់នោះដូចម្ដេចទៅ? តាមសេចក្ដីពិតសំណាងជាក្មេងស្រឡាញ់ឪពុករបស់ខ្លួន កាលបើបាត់មិនឃើញឪពុក អ្នកតែងតែចេញដើររក ជាគ្រោះល្អ

(នៅមានត)

## សមាគមមិត្តសាលាបាលី ឆ្នាំ ១៩៥៤

**ក្រុមអភិបាល**

លោក ក៉យ-ប៊ុក អធិបតី
" សម-ចាន់ អធិបតីរង
អ្នកស្រី គង់-ស "
លោក ផេង-ជ្រឿវ លេខាធិការ
" តែ-ផុន អនុលេខាធិការ
" ម៉ម-ម៉ែម "
" អ៊ុច-រស់ អគ្គហេរញ្ញិក
" ម៉ៅ-ម៉ី អនុហេរញ្ញិក
អ្នកស្រី លេខា "
លោក ចាប-ពិន បណ្ណារក្ស
" មាស-ម៉ន "

**ទីប្រឹក្សា បុមភាព**

ឯកឧត្ដម សំ-ញាណ
លោក ស្វាយ-ភ៉ី
" អ៊ូ-គង់
" កែប-អ៊ុល
" ថៃ-លី
" អ៊ុក-ឆង់
" ប៉ក់-សមេត
" ញ៉ង-សៀង
" ភ៉-ស៊ុយន
" សាម-ឡាមុត
" បិង-ហ៊ាត
" ឌី-ផុន
" ហ្វូត-ហៀម

**ទីប្រឹក្សា ឥត្ថីភាព**

អ្នកស្រី ក៉យ-ប៊ុក អ្នកស្រី ស្វូ-កី
" ទេព្វាសិកា ពិន

## យោបល់អ្នកការពារ

ខ្ញុំបាទសូមជូនសេចក្ដីចំពោះលោក-អ្នកអានទាំងឡាយ, ទស្សនាវដ្ដីមិត្តសាលាបាលី មិនមែនជារបស់ឯកជនឡើយ គឺជារបស់នៃអស់លោកជាមិត្តទាំងឡាយ ដោយហេតុនេះ អស់លោកត្រូវមានសិទ្ធិជូនគំនិត: បន្ទោសចំពោះករណីយកិច្ចនៃមាតិការឿងមួយៗដែលពុំគាប់ចិត្ត សរសើរមាតិកាណាដែលមិត្តចូលចិត្តអាន, មិត្ត-ត្រូវដាក់ពិន្ទុហើយផ្ញើត្រឡប់ទៅកាន់ទីចាត់ការទស្សនាវដ្ដីវិញ ។

## សិទ្ធិនៃការសរសេរ

មិត្តទាំងឡាយមានអំណាចសរសេររឿងណាមួយ ដែលមិត្តមានបំណងបង់ចុះក្នុងទស្សនាវដ្ដីមិត្តយើងនេះ មិត្តមានអំណាចប្រកែកទល់នឹងយើងខ្ញុំជាគណៈកម្មការដែរ ភេទដែលគក់តាមផ្លូវលិខិតបាន; ទីបំផុតគណៈកម្មការសូមអញ្ជើញអោយលោកជាមិត្តសរសេរយោបល់ផ្ញើទៅគណៈកម្មការ ដើម្បីខ្ញុំនឹងបានចុះផ្សាយតាមការណ៍ ។

កន្លងឆ្នាំនេះ បរិសទ្យអ្នកតាចិនដូចជាមានចំនួនក្រាស់ក្រែល ប្រជាជនខ្មែរជាច្រើនបានទៅជួយហែក្បួនពិធីបុណ្យនោះដែរ ។ ដោយសេចក្ដីជ្រះថ្លាចំពោះលោកអ្នកតាចិន បរិសទ្យទាំងឡាយសុំលះបង់សេចក្ដីនឿយហត់ចេញចាកគេហដ្ឋាន តាំងពីពេលដែលព្រះធាតុត្រូវគេបញ្ចុះបញ្ចូលនៅយ៉ាងអស្ចារ្យ ក្នុងវត្តមួយៗ ប្រជាជនប្រញាប់ប្រញាល់ ប្រារព្ធពិធីការហែព្រះបរមសារីរិកធាតុ នេះជាសាមគ្គីធម៌របស់ពុទ្ធបរិស័ទខ្មែរ ក្នុងពិធីហែព្រះពុទ្ធបដិមាករ ឬហៅថា កប៉ាន គេបានឃើញបរិសទ្យអ្នកតាចិន ក្ដៅក្រហាយក្នុងការហែនៃពុទ្ធបរិសទ្យដែរឬទេ ?



ការនិមន្តជាអធិបតីភាពនៃសម្ដេចព្រះមហាសុមេ-ធាធិបតី ក្នុងពិធីទទួលព្រះមហាធម្មវររីមហាថេរ ដែលនិមន្តមកដល់ប្រទេសកម្ពុជា ជាប្រតិភូពុទ្ធិកសមាគមពិភពលោក អនាសោភាគម ដែនញូវដែលី ប្រទេសឥណ្ឌា ពីថ្ងៃអង្គារ ៨ មករា ឆ្នាំ ១៩៥៤ ម៉ោង ១៦ (ម៉ោង ៤ រសៀល) នៅទីបំណាត អាកាសយានដ្ឋានពោធិ៍ចិនតុង ។

ព្រះធម្មវររីមហាថេរ ប្រតិភូពុទ្ធិកសមាគម ពិភពលោក និមន្តមកដល់មុខមហាកុដិ សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក វត្តឧណ្ណាលោម ។



ស័ក្តព្រះសង្ឃ ដែលផ្ញើយ ៗ ត្រូវស្គាល់ស័ក្ត តាមភាពមកក្នុងដងតានី ច្រើនគេតែពោលថា ប៉ុន្តែ បើស័ក្តបម្រើដំនឹងគួរត្រូវ គេថា ពាក់ នៅមានជនចំពួកខ្លះទៀតតែការគិត គេថា ស័ក្តព្រះសង្ឃពាក់ បម្រើនឹងគួរត្រូវ ប៉ុន្តែទៅវិញ ចុះឲ្យខ្ញុំយល់តាមជនចំពួកណា ? អ្នកដែលថា ពាក់នោះ ដោយហេតុអ្វី? ថាប៉ុន្តែនោះគេទាស់ការណ៍ដូចម្ដេច ?